ការសម្ភាសរបស់បងស្រី ហេង ផល្លា

កៈអ្នកធ្វើការសម្ភាសឈ្មោះ ហេង សុជីវី ខៈអ្នកដែលត្រូវបានគេសម្ភាសឈ្មោះ ហេង ផល្លា

ការសង្ខេបរបស់បងស្រី ហេង ផល្លា

បងស្រីហេង ផល្លាមានអាយុ៥០ឆ្នាំ កើតនៅក្នុងឆ្នាំចរ ថ្ងៃទី៨កើត ខែជេស នៅក្នុងឆ្នាំ១៩៧០។ ការសម្ភាសនៅក្នុងថ្ងៃទី១ មិថុនា ឆ្នាំ២០១៩។ មានម្តាយឈ្មោះប៉ាចនិងឪពុកឈ្មោះ ហេងស្ប៊ីន ជាអតិតទាហានសកម្រាំងរបស់បារាំង បងស្រីមានបងប្អូន៥នាក់ ស្រី៣ប្រុស២នាក់។ សព្វថ្ងៃឪពុកម្តាយរបស់បងស្រីបានស្លាប់អស់ហើយ តែកាលពីពួកគាត់នៅមានជីវិតនៅរស់បងស្រីបានទទួលបន្ទុកចិញ្ចឹមឪពុកម្តាយចាស់ជរា បងស្រីបានរៀបការជាមួយនឹងស្វាមីដោយស្របច្បាប់ ដល់ពេលបងស្រីបានកូនប្រុស១អាយុ៥ខែ ក៏បងស្រីបានបែកជាមួយនឹងប្តីពីភ្នំពេញមកយកកូនអោយម្តាយមើលនៅឯស្រុក ដល់ពេលក្រោយមកបងស្រីអាយុបានន៥០ឆ្នាំម្តាយបងស្រីស្លាប់ ហើយបងស្រីក៏បានយកប្តីម្នាក់ទៀត ដែលឈ្មោះតាកុយ អាយុ៥៧ឆ្នាំ។

កៈ ចាស! ខ្ញុំជំរាបរលឹកបងស្រី តើបងស្រីសព្វថ្ងៃសុខសប្បាយដែរទេ?
ខៈ សុខសប្បាយទេ!
កៈ ចាស! ខ្ញុំឈ្មោះកុយ សុភី
បានមកជួបបងស្រីគឺមានគោលបំណងសុំការអនុញ្ញាតសម្ភាស នៅឆ្នាំការ ឯស័កពុទ្ធសារាជ ២៥៦៣ ខែពិសាខ ១៤រោច ត្រូវនឹងថ្ងៃ សៅរ៍ទី១ ខែមិថុនា ឆ្នាំ២០១៩។ នាមត្រកូលបងស្រីឈ្មោះអ្វី?
ខៈ ហេងស្រីពៅ!
កៈ ចាស! ឈ្មោះហ្នឹងអ្នកណាជាអ្នកដាក់ឈ្មោះអោយដល់បងស្រី?
ខៈ អឺ! ម្តាយឪ!
កៈ តើសព្វថ្ងៃ បងស្រីមានឈ្មោះហៅក្រៅ១ទៀតដេស?
ខៈ សព្វថ្ងៃហៅអាហ្នឹង បើសិនជាឈ្មោះដើម ហេងផល្លា ឈ្មោះកំណើតតែម្តងហេងផល្លា និងឈ្មោះក្រៅឈ្មោះ ហេងស្រីពៅ។
កៈ អូ! ចឹងហេងផល្លានុងគឺ ដាក់នៅក្នុងអត្តសញ្ញាណប័ត្រជាផ្លូវការហ៉ា?
ខៈ ចាស!
កៈ ចាស! ហើយចឹងនេះឈ្មោះ ហេងស្រីពៅ ហៅក្រៅទេ?
ខៈ ចាស!
កៈ ចាស! អឺ! បងស្រីកើតនៅខែឆ្នាំខែណា?
ខៈ កើតនៅឆ្នាំ ៧០!
កៈ អូ! ចុះឆ្នាំខ្មែរវិញ តើឆ្នាំអ្វី?
ខៈ ឆ្នាំខ្មែរ ខែជេស ខែ៦ ថ្ងៃ៨កើត ខែជេស។
កៈ ឆ្នាំ?
ខៈ ចំថ្ងៃពុធ!
កៈ ឆ្នាំគេហៅឆ្នាំអីដែរ?
ខៈ ឆ្នាំ ហៅគេឆ្នាំចរ!
កៈ ឆ្នាំចរ ចឹងបងស្រីសព្វថ្ងៃអាយុហា?
ខៈ ហាសិប!
កៈ ហាសិបគត់! ចាស! ហាសិបហើយនេស?
ខៈ ចាស!
កៈ តើបងស្រីមានសញ្ជាតិជាខ្មែរ?
ខៈ សញ្ជាតិខ្មែរហ្នឹង!
កៈ កាន់សាសនាអ្វី?

ខ៖ សាសនាខ្មែរ!
ក៖ ចាស! កានសាសនាព្រះពុទ្ធចឹងណ៎?
ខ៖ ចាស!
ក៖ ចាសអឺ! បងស្រីកាលពីនៅក្មេង បងមានបានចូលសិក្សាដេស?
ខ៖ ចូលសិក្សាចប់ត្រឹមថ្នាក់ទី៤។ ថ្នាក់ទី៤ក៏ប៉ុន្តែម៉ាជំនាន់ខ្ញុំរៀននុង តែថ្នាក់ទី៧ ធ្វើគ្រូ ៧បូកពានោះ បានប្រឡងជាប់គ្រូ។
ក៖ ចឹងកាលនុងជាជំនាន់គេហៅថាឌីផ្លូម មិនមែនបាក់ឌុបទេ?
ខ៖ ហ្នឹងហើយឌីផ្លូមបាក់ឌុបហ៎។
ក៖ គេរៀនត្រឹមថ្នាក់ទី៥!
ខ៖ អាក្រោមនេះត្រឹមថ្នាក់ទី៥ ទី៤អីនុង ទី៥!
ក៖ចឹងពេលនុងគេហៅថាប្រឡងចូលកាលេសនេស?
ខ៖ ចាស!
ក៖ ចាសចូលទី៧ទី៨គេហៅប្រឡង ឌីផ្លូម?
ខ៖ ឌីផ្លូម!
ក៖ ឌីផ្លូមចឹងកាលនុងគឺ អោយតែប្រឡងជាប់យើងចង់ធ្វើគ្រូអីនុង ទិញពាក្យ ទៅប្រឡងគ្រូទៅ?
ខ៖ ហ្នឹងហើយ ទៅប្រឡងគ្រូទៅ។
ក៖ ចាស! ប៉ុន្តែបងស្រីបានឈប់រៀនត្រឹមថ្នាក់ពី៤ហ៎?
ខ៖ ត្រឹមថ្នាក់ទី៤!
ក៖ហើយទៅរៀននៅសាលាណា?
ខ៖ ចប់ត្រឹមទី៥ឈប់! សាលាពោធិគ្រង។
ក៖ សាលានុងនៅក្នុងខេត្តអ្វី?
ខ៖ សាលានុងនៅក្នុងខេត្តកំពង់ចាមហ្នឹង! ស្រុកព្រៃឈរ ខេត្តកំពង់ចាម។
ក៖ អូ! ចឹងបងស្រីមានទីកន្លែងកំណើតកើតណានៅក្នុងភូមិ?
ខ៖ ភូមិអំពីធំ! ឃុំឃ្វិតធំ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។
ក៖ រួចទៅ
មូលហេតុអ្វីដែរបានជាបងស្រីពេលបច្ចុប្បន្ននេះបងស្រីមកនៅក្នុងឃុំអី?
ខ៖ ឃុំពោធិ៍សាលា!
ក៖ មកនៅពោធិ៍សាលាវិញ?
ខ៖ មកពីមានប្តី! មានគ្រួសារមក! មានគ្រួសារមកខាងពោធិ៍សាលាវិញ លែងនៅអំពិលធំហើយ។
ក៖ ចឹងមានគ្រួសារមកនៅហ្នឹងបានរយៈពេលប៉ុន្មានឆ្នាំហើយ?
ខ៖ មិនទាន់ទើបតែបានប្រហែលជាប្រម៉ាខែទើបតែខែ១ មកដល់ខែ...
ក៖ ខែ១ ឆ្នាំ២០១៩ហ៎?
ខ៖ ចាស!
ក៖ អូ...ចាសរួចទៅគ្រួសារបងស្រីឈ្មោះអ្វី?
ខ៖ កុយ!
ក៖ ត្រកូលរបស់គាត់?
ខ៖ ចាស!
ក៖ តើត្រកូលរបស់គាត់ឈ្មោះអ្វី?
ខ៖ ត្រកូលគាត់ឈ្មោះអី? ស្ងួង !
ក៖ ស្ងួង កុយចឹង?
ខ៖ ស្ងួងកុយ! ត្រកូលរបស់គាត់!
ក៖ ចាស! រួចចុះស្រុកកំណើតរបស់គាត់នៅឯណាដែរ?
ខ៖ នៅពោធិ៍សាលាហ្នឹង! ហើយបានមកអឺ...ស្រុក!
ក៖ រួចមកឃុំ ។
ខ៖ ឃុំសៀមរាប!

ក៖ ឃុំសៀមរាបហើយមកស្រុក?
ខ៖ ស្រុក...។
ក៖ ស្រុកកំពង់កន្ជួត!
ខ៖ ស្រុកកំពង់កន្ជួត! ខេត្តសៀមរាប!
ក៖ អត់នោះទេ! ខេត្តកណ្ដាល!
ក៖ ឃុំសៀមរាប!
ខ៖ ឃុំសៀមរាប!
ក៖ ហ្នឹងហើយឃុំសៀមរាប នៅក្នុងខេត្តកណ្ដាល!
ខ៖ ឃុំសៀមរាប ខេត្តកណ្ដាល។
ក៖ ចាស!ប៉ុន្តែដល់ពេលតើមានមូលហេតុអ្វី
ដែលពេលបច្ចុប្បន្នឥឡូវនេះគាត់មកពីឃុំសៀមរាប ខេត្តកណ្ដាល
មកនៅខេត្តកំពង់ចាមនេះវិញ?
ខ៖ មូលហេតុគាត់មានប្រពន្ធ! មានប្រពន្ធមកនៅខាងពោធិសាលានេះវិញ
ចឹងហើយក៏មិនមកតាមប្រពន្ធ!
ក៖អូ! ចឹងគាត់មានប្រពន្ធមុនអីដែរហ៎?
ខ៖ មានប្រពន្ធមុនអីដែរក៏ប៉ុន្តែបានស្លាប់!
ក៖ អូ...ចឹងគាត់មានប្រពន្ធមុននុងមានស្រុកកំណើតនៅពោធិសាលា!
ខ៖ នៅពោធិសាលា!
ក៖ ចឹងប្រពន្ធមុននុងនៅពោធិសាលានុង?
ខ៖ ចាស!
ក៖ ចឹង!
ចឹងទីតាំងកន្លែងនេះចឹងជាទីតាំងកំណើតខាងប្រពន្ធគាត់នោះទេចឹង!
ខ៖ ខាងប្រពន្ធដើម ទីតាំងរស់នៅហ្នឹងក្បែរដំណេលពីគាត់
បានមានទីជាមួយនឹងគ្នា បានចាប់ដៃគ្នារកនោះ។
ក៖ ចឹងហ៎ មានក្បែរដំណេល!
ខ៖ មិនមែនក្បែរដំណេលនោះទេ គាត់បានខំប្រឹងរកស៊ីចាប់ដៃគ្នាមក។
ក៖ អូ!
ខ៖ ក៏ប៉ុន្តែកាលនៅប្រពន្ធមុនៗនុងមេម៉ាយកូន៣។
ក៖ ចឹងហើយគាត់ស្លាប់ណ៎?
ខ៖ ហ្នឹងហើយ!
ក៖ តើគាត់បានស្លាប់ដោយសារតែមានមូលហេតុអ្វី?
ខ៖ ស្លាប់ដោយសារតែទឹកនោមផ្អែម!
ក៖
ហើយមានបានដឹងថាគាត់បានស្លាប់នៅអាយុប៉ុន្មានដែរប្រពន្ធដើមរបស់គាត់?
ខ៖ ៦០! គាត់បានប្រាប់ដល់ខ្ញុំថាអាយុ៦០។
ក៖ ៦០! ហើយគាត់បានកូន៥ហ៎?
ខ៖ គាត់បានកូនប៉ុន្មាននោះទេ ដូច៣ហេស! យកប្រពន្ធក្រោយនេះហ្នឹង
តើ៤ឬក៏៣?
ក៖ ៤!
ខ៖ អើ! បានកូន៣!
ក៖ ចឹងបងស្រីមានបានចាំអត់ថា តើកូនដើមរបស់គាត់មានឈ្មោះអ្វី?
ខ៖ សំរាប់កូនប្រពន្ធដើម
ឈ្មោះដើមគេនុងមិនដឹងថាឈ្មោះអីនោះទេអត់មានបានចាំនោះទេ
មានប្រពន្ធដើមនោះដល់ទៅ៣នាក់ តែអត់បានចាំ! ចាំតែ១នាក់នោះទេ ឈ្មោះ
ហ៉ា!។
ក៖ ឈ្មោះថា ហ៉ាហ៎!
ខ៖ ឈ្មោះហ៉ា ជាម្តាយឪមីមួយនេះ!

ក៖ ចាស!
ខ៖ ចាំតែ១ហ្នឹងនោះទេ!
ក៖ ដល់ពេលគាត់មេម៉ាយ
ដឹងថាគាត់បានមេម៉ាយបានប៉ុន្នានឆ្នាំដែរបានមកជួបនឹងបងស្រីទៀត?
ខ៖ ប្រហែលជាងបាន១ឆ្នាំអីនោះទេ។
ក៖ ចាសចឹងបានជាង១ឆ្នាំហ៍?
ខ៖ ចាសបានជាង១ឆ្នាំ ជិត២ឆ្នាំនោះហើយ។
ក៖ រួចទៅហ្នឹងហើយ ឥឡូវចូលនិយាយអំពីបងស្រី
តើមានមូលហេតុអ្វីបានគាត់ជួបបងស្រី?
ខ៖ មូលហេតុនុង ខ្ញុំគេនាំមកដុតពោតនៅឯកើត! នៅចំការខាងកើត។
ក៖ នៅខាងកើតកន្លែងធ្វើចំការ!
ខ៖ ចាស! នៅខាងកើត នៅត្រាយខាងកើតទៀត!
រួចទៅខ្ញុំនេះក៏លក់ឥវ៉ាន់នៅខាងខ្វិននុងនោះ។
ក៖ ចាស!
ខ៖ យកទៅលក់ចឹងទៅខ្ញុំនេះក៏ថា! អឹម អត់មានបានដើរលេងនោះទេ
ព្រោះអីខ្ញុំនេះអត់ ខ្ញុំជំពាក់គេ ខ្ញុំអត់មានលុយ
កាលណាតែដើរទៅខ្ញុំអត់មានលុយយកសងគេនោះទេ
រួចចឹងទៅក៏លក់ដូងនុងអស់ លក់ដូងនុងបាន៥០ផ្លែអស់ចឹងទៅ គេបបួលដើរ។
គេបានបបួលថាតោះ! ទៅដុតពោត ម៉ោង១១ហើយទៅ។
អស់ដូងអស់អីលក់ហើយនោះ ដល់ចឹងទៅក៏មកតាមគេ។
ក៖ ចាស!
ខ៖ ដល់ពេលមកតាមគេនុង មកដល់ចំការ!
ក៖ កាលនុងមកនុងអស់ដូងអស់អីរលីងនុងប្រហែលជាម៉ោងប៉ុន្នានដែរ?
ខ៖ ម៉ោង១១!
ក៖ ម៉ោង១១ ថ្ងៃត្រង់!
ខ៖ ដល់ពេលម៉ោង១១នុងបានចេញមកលេងហ្នឹង ដើរមកដុតពោត ដុតអីនុង
បានជួបគាត់ហ្នឹងម៉ោងពាល្វាចហើយរៀបនឹងទៅវិញនុង។
ក៖ ចាស!
ខ៖ ហើយអាចៅនិងក្មួយនុងដឹកតាទៅចំការនៅកើតនុង ទៅអោយមើល!
ក៖ ចាស
ខ៖ អើ! ទៅអោយមើលចឹង
ត្រាន់តែថាជិតទៅដល់នៅកន្លែងផ្លូវតែខ្ញុំអង្គុយចឹងទៅ
ក៏គាត់ថានឹងតូអញហើយ អញដឹងតែយកហើយ ព្រោះអីគាត់ស្លៀកក្រមានោះទេ
ទៅមើលនុងហ៍! ។
ក៖ ហាស។!
ខ៖ ស្លៀកក្រមាហើយស្រវឹងឡើងអូម!
ក៖ ស្រវឹកទៀត! ស្លៀកក្រមានុងក៏ប៉ុន្តែមានបានពាក់អាវដែរឬក៏អត់?
ខ៖ ពាក់អាវ!
ក៖ ពាក់អាវហ៍តើចាំហេស?
ខ៖ពាក់អាអាវធំនេះ! អាអាវធំគាត់នេះ!
ក៖ អឺ! អាអាវត្រីអ៊ីនុងហេស?
ខ៖ អឹម! រួចទៅខ្ញុំថា ខ្ញុំមិនស្រលាញ់នោះទេ អាតានុងស្រវឹកអែលនុងហ៍
តែមិនដឹងជាយ៉ាងម៉េចស្រាប់តែខ្ញុំឡើងជិះម៉ូតូមក
គាត់យកដៃទះស្មារបស់ខ្ញុំពាដង ជាត់។ចឹងពាដង។
ក៖ រ៉ៃស្មាហ្នឹងចឹង!

ខ៖ ហ្នឹងហើយ! ដល់ចឹងក៏នឹកអាណិតគាត់ គឺមានចិត្តស្រលាញ់ចឹង! ទៅចឹងណា!
កាលពីមុនដំបូងនោះអត់មានបានស្រលាញ់នោះទេ
ព្រោះអីគាត់ស្រវឹកស្រាឡើងអួម! ។
ក៖ អូ ចឹងបានគាត់ទះស្មានុងចឹងទៅស្រាប់តែនឹកអានិតគាត់!
ខ៖ នឹកអាណិតហើយស្រលាញ់គាត់តែម្តង! ដល់ពេលស្រលាញ់ទៅ
ហើយគាត់ស្លរអីចឹងទៅ ក៏ដើរលេងដល់កន្លែងខ្ញុំលក់! ។
ក៖ ដល់ពេលក្រោយមកនោះទេហេស?
ខ៖ ចាស! ដល់ពេលថ្ងៃស្អែកឡើង។
ក៖ ចឹងដល់ពេលស្អែកឡើងចឹងម៉េច?
ខ៖ ដល់ពេលស្អែកឡើងទៅដល់ ហើយនិយាយលិចកើតចឹងទៅក៏
ខ្ញុំបានប្រាប់គាត់តាមត្រង់ថា ខ្ញុំគ្មានលុយនោះទេ ខ្ញុំក្រនោះទេ ដីក៏ខ្ញុំគ្មាននៅ
ផ្ទះក៏ខ្ញុំគ្មានដែរ ខ្ញុំនៅផ្ទះបងនោះទេ ខ្ញុំក្រណាស់ ខ្ញុំចិញ្ចឹមម្តាយ
ទាល់តែឱពុកម្តាយចាស់ៗគាត់បានស្លាប់!
ដល់ពេលគាត់ស្លាប់ទៅអស់លុយតែម្តងគ្មានលុយនោះទេ
តែ១០០នៅក្នុងខ្លួនក៏គ្មានដែរ ក៏ជំពាក់គេដែរ
បានជំពាក់គេឡើង២០០០នោះសងគេមិនរួចនោះទេ
បើសិនជាខ្ញុំស្រលាញ់នោះខ្ញុំស្រលាញ់ហើយ ក៏ប៉ុន្តែខ្ញុំក្រ ខ្ញុំអត់លុយ
កុំអោយដល់ពេល! ...កុំអោយដល់ពេលបានគ្នាចឹងទៅ
ដៀលគេចឹងទៅវាក្រអីចឹងណា ហើយសុំអោយគាត់ប្រណីចឹងណា
ដល់ចឹងគាត់ក៏ថាគាត់ក៏មិនដៀលនោះដែរ ព្រោះអីគាត់នៅចេញសងចឹងណា
គាត់ជួយសងគាត់ជួយអីចឹងទៅ ព្រោះអីគាត់មានចិត្តនោះហើយ
នាំទៅមើលនៅកន្លែងណាក៏មិនត្រូវទៅមើលនៅកន្លែងណាក៏មិនបានត្រូវនោះដែ
រ ហើយដល់ពេលចំខ្ញុំនុងគាត់ក៏ពេញចិត្តថានេះហើយគូខ្ញុំហើយ
នេះគូគាត់ហើយចឹង។
ក៖ ចាស។
ខ៖ ក៏! ចឹងទៅមានគេបំបែកទៀត! មានគេបំបែកមិនអោយជួបគាត់នោះទៀត
និយាយអាក្រក់ៗពីខ្ញុំសុតតែគ្មានដី គ្មានផ្ទះ គ្មានលុយកាកអីនៅសល់នោះទេ
ចឹងកុំយកវា សុតតែស្អី!ៗទៀត វាក្រអីចឹង និយាយអំពីខ្ញុំនឹងទៅប្រាប់គាត់
តែគាត់ថាក្រក៏ដោយ គាត់រកតែអ្នកក្រនោះទេ មករកស្រីទាំងអស់គ្នាទៅ
ក៏គាត់អត់តាមគេនោះដែរ គាត់តាមដណ្តឹងខ្ញុំនឹងទាល់តែបាន
ទាល់តែថាខ្ញុំយក។
ក៖ ចឹងតើរយ:ពេលយូរដេសបងស្រីដែរថា...។
ខ៖ យូរមួយរយ:!
ក៖ មុននឹងគាត់បានចូលទៅស្តីដណ្តឹងដល់បងស្រីនៅរយ:ពេលប៉ុន្នានដែរ?
ខ៖ អឹម! រយ:ពេល បើសិនជាត្រឹមបានន៧មកវាមក
គឺត្រឹមស្រលាញ់ត្រឹមពី៧មកវានុងមក ត្រឹមដល់ថ្ងៃទី២០ ខែ៧មកវានុង
ទាល់តែដល់ថ្ងៃ២០ខែ២នុង។ តើ៧មកវាខែ២ហេស?
ក៖ ៧មកវា ខែ១!
ខ៖ ហេសខែ២ហេស?
ក៖ ខែ១!
ខ៖ ខែ១?
ក៖ ចាស!
ខ៖ ដល់ពេលថ្ងៃ២០ខែ១បានខ្ញុំការនុង!
ក៖ អូ! ចឹងគាត់ជូនជំនួន និយាយទៅថ្លៃទឹកដោះនោះបានប៉ុន្នានដែរ?
ខ៖ គាត់ជូនថ្លៃទឹកដោះនុងបាន៥០០!
ក៖ ៥០០!
ខ៖ បាន៥០០នុងគាត់បានយកទៅសងគេអស់!

ក៖ ប៉ុន្តែការនុង នៅកន្លែងភូមិរបស់បងស្រី?
ខ៖ ការនៅឯហ្នឹង!
ក៖ ចឹងមកការនៅខាងប្រុសវិញ?
ខ៖ បើសិនជាខ្ញុំអត់មានផ្ទះនោះផង!
ក៖ ចឹង!
ខ៖ ខ្ញុំអត់មានផ្ទះ អត់មានដីនុងហើយ!
ផ្ទះមានផ្ទះឯណាការចឹងបានជាការនៅផ្ទះគាត់នុង
គាត់សុតចិត្តយកមកការនៅផ្ទះគាត់! គាត់អាណិតយើញថាយើងអត់។
ក៖ ដល់ពេលគាត់ចឹងហើយបងស្រី
កាលនុងដូចថាកាលនុងខាងបងស្រីបានហូបប៉ុន្មានតុ?
ខ៖ គាត់ថាធ្វើទាំងអស់ហូប៣០តុ! គាត់ថាប្រាប់ភ្ជៀរប៉ុន្មាននោះប្រាប់ទៅ
គាត់ដឹងតែថាគាត់ធ្វើអោយ៣០តុ! ប៉ុន្តែដល់ពេលប្រាប់ទៅ បងប្អូនរបស់ខ្ញុំមក
ខ្ញុំវបានប្រាប់គាត់ត្រង់ថាយើងនេះក្រអីចឹងស្អីចឹង! គាត់ថា គាត់មិនទៅថាអីដែរ
ហើយគាត់បានដឹងថាជីវិតរបស់ខ្ញុំនេះវាវេទនាចិញ្ចឹមចាស់នោះ ចឹងចិញ្ចឹមចាស់
ឪពុកម្តាយរបស់ខ្ញុំសុតតែអាយុ៨០ជាង
រួចឪពុកម្តាយរបស់ខ្ញុំគាត់បានទៅនៅឯខាងប្អូនបងខ្ញុំនោះទេ
ខ្ញុំក្រហើយតែគាត់នៅតែនៅជាមួយនឹងខ្ញុំហ្នឹង ដល់ពេលហើយលក់បានព្រឹកហ្នឹង!
ដល់ពេលចឹងហើយខ្ញុំបានថា
អោយគាត់ទៅនៅជាមួយនឹងបងៗតែគាត់ថាមិនទៅនោះទេ!គាត់អត់ទៅនោះ
ទេ គាត់នៅជាមួយនឹងកូនៗនោះទេ គាត់នៅតែជាមួយនឹងកូនពៅហ្នឹង!
គាត់ស្លាប់តែនៅលើដែនុងណា
ហើយដល់ពេលគេប្រាប់ដល់អាចារ្យនោះខ្ញុំទៅរួចហេស តែ២នាក់ចឹងហ៎ !
ចឹងបានថា
ទាល់តែគេប្រាប់ដល់ចាស់ៗនុងបានគេប្រាប់តាអាចារ្យថាម្តាយរបស់ខ្ញុំ
ដាច់ខ្យល់ហើយលោកតាអាចារ្យអញ្ជើញមក
សក់ក្បាលឡើងរីងកាត្រីសដូចជាឫស្សីចឹងតែ២នាក់គឺថាតែទាល់ទាលចឹងណា
កំសត់ណាស់។
ក៖ចឹងខ្លាចសពម្តាយដែរ គាត់ស្លាប់ហើយនុង?
ខ៖ ខ្លាចដែរនុងណា! ចឹងសក់ឡើងបាស់! ឡើងចឹងហ៎ ឡើងរីងតែម្តង ឡើងញ័រ
បើសិនជាគេគាំងបេះដូងនោះគេខ្សោយងាប់ដែរហើយ តែខ្ញុំអត់ខ្សោយបេះដូង
ដល់ពេលចឹងគាត់ដើរទៅគាត់បានដើរផ្អែង ដល់ពេលខ្ញុំទាញគាត់ចឹងមក
ស្រាប់តែគាត់ភ្ញែកឡើងស្លើ! ដាក់ចឹងណា!
ក៖ ហ្នឹងហើយ!
ខ៖ ដល់ពេលចឹងបើសិនជាអ្នកបេះដូងខ្សោយនោះគឺគាំងដែរហើយ
តែខ្ញុំស្ទារតីរីង ដល់ពេលស្ទារតីរីងហើយអោយគាត់ទន្ទេញធម៌
ប្រាប់គាត់ថាម៉ាក់អា សូត្រធ៌ទៅផ្លូវណាដែរទៅរួច មានតែពុទ្ធធោ!នោះទេ
ទន្ទេញទៅបានដើរទៅរួច បានទាំងផ្លូវម៉ែឯងទៅរួចចឹងម៉ែឯងទន្ទេញធម៌ទៅ
កាលនុងខ្ញុំតែ២នាក់គាត់ ខ្ញុំកំសត់មែនទែន ហើយគេធ្វើបាបទៀត
គេធ្វើបាបណាស់។
ក៖ តើឪពុកម្តាយរបស់បងស្រីឈ្មោះអ្វី?
ខ៖ឈ្មោះ អ៊ុងប៉ាច !
ក៖ អាយុរបស់គាត់?
ខ៖ ៨៤!
ក៖ គឺស្លាប់នៅ៨៤ហ៎?
ខ៖ ចាស!
ក៖ អឹម! រួចទៅបងប្អូនខាងម្តាយនឹងឈ្មោះអ្វីគេខ្លះមានបានចាំដែស?
ខ៖ ដើមទីគេបង្អស់ឈ្មោះហេងស្រីរី!

ក៖ ស្រីហេស? ភេទស្រីហេស?
ខ៖ ចាស! ហើយមកដល់ទី២ហេងសម្បត្តិ! ភេទប្រុស!
ហើយបានទី៣ហេងសំបូរនេះ នៅខាងជើងនេះ រួចមកអាទី៤នុង ហេងស្រីមុំ
ហើយបានជាមកខ្ញុំក្រោយគេនេះហេងស្រីពៅ!។ បងប្អូនរបស់ខ្ញុំ៥នាក់ទាំងអស់!
ក៖ ចឹងបងប្អូនរបស់បងស្រីមាន៥នាក់ណា!
ខ៖ ចាស! ស្រី៣ ប្រុស២។
ក៖ ចឹងខ្ញុំសួរបងប្អូនខាងម្តាយរបស់បងស្រីណា!
ខ៖ ចាស!
ក៖ ឥឡូវថាបងប្អូនខាងបងស្រីហ្នឹងគឺមានគ្នា៥នាក់នេស?
ខ៖ ចាស!
ក៖ ចាសប៉ុន្តែចំណែកឯខាងម្តាយបងប្អូនរបស់ខាងម្តាយបងស្រីហ្នឹង?
ខ៖ មាន៣នាក់!
ក៖ មានតែ៣នាក់នោះទេហេស?
ខ៖ ចាស!
ក៖ តើមានឈ្មោះអ្វីគេខ្លះ?
ខ៖ ឈ្មោះអឺយ! បងគាត់ ត្រូវជាបងរបស់ម្តាយខ្ញុំនុងឈ្មោះតាសំ
រួចបន្ទាប់មកគាត់នុង យាយប៉ាច ហើយដល់ពេលប្អូនពៅរបស់គាត់នុង ឈ្មោះ
តានោល តែ៣នាក់នោះទេ បងប្អូនរបស់គាត់នោះ។
ក៖ រួចចុះឱពុករបស់បងស្រីឈ្មោះអ្វី?
ខ៖ ឱពុករបស់ខ្ញុំឈ្មោះតាស្ប៊ុន ឈ្មោះ ហេងស្ប៊ុន។
ក៖ តើគាត់ស្លាប់នៅអាយុប៉ុន្នានដែរ?
ខ៖ គាត់ស្លាប់នៅអាយុ៧៧ កាល២០១៣ គាត់បានស្លាប់។
ក៖ ចឹងស្រុកកំណើតរបស់គាត់នៅជាមួយ?
ខ៖ ស្រុកកំណើតរបស់គាត់នៅឯខាងសួង ឯណោះ នៅខាងជុប សួង
ស្រុកកំណើតរបស់គាត់។
ក៖គាត់មានដែលបានប្រាប់បងស្រី
តើមានមូលហេតុអ្វីបានជាឱពុកម្តាយនឹងគាត់បានរៀបការជាមួយ
តើត្រូវជាប់សាច់ឈាមបងប្អូនឬក៏យ៉ាងម៉េចដែរ?
ខ៖ ជាប់សាច់ឈាមបងប្អូនដែរក៏ប៉ុន្តែត្រូវជាសាច់ឆ្វាយចឹងណា
ហើយទៅខាងឱពុកនិងម្តាយរបស់ខ្ញុំនុង
ក៏ត្រូវជាជាប់បងប្អូននោះដែរក៏ប៉ុន្តែសាច់ឆ្វាយដូចថាជីទួត១ចឹងណា
គាត់ភ្ជាប់កុង ម៉ៅខ្ញុំនុង គាត់ភ្ជាប់ទៅ
ព្រោះអឺបងប្អូនរបស់គាត់នុងនៅឯខាងល្វានៅតាគោកនុង គាត់នៅខាងនុង
បងប្អូនខាងតារបស់ខ្ញុំកុងខ្ញុំហ្នឹង។
ក៖ ចាស។
ខ៖ គាត់ឈ្មោះ កុងម៉ៅ កុងហាក់!
ក៖ អូ! រួចទៅអឺ! ចុះបងប្អូនខាងឱពុកបងស្រីនុង តើមានគ្នាប៉ុន្នាននាក់ដែរ?
ខ៖ ៧នាក់ប៉ុន្តែអត់ចាំនោះទេ! ចាំបានតែ៣នាក់នោះទេ!។
ក៖ តើឈ្មោះអឺ?
ខ៖ គឺកុងហាក់ កុងហេងនុង៣!
ក៖ ចាស!
ខ៖ រួចហើយកុងម៉ៅ! បាប៣នាក់ហ្នឹង។
ក៖ ចឹងនេះបងប្អូនបង្កើត?
ខ៖ ចាសបង្កើត! នេះខាងឱពុកបង្កើតៗ ដូចជាគាត់ខាងឯជុបនោះ
ខាងជើងនៅទឹកចេញ។ គាត់នៅខាងនុង!
ហើយនេះតាមម្តាយខ្ញុំគាត់ដំណាលប្រាប់ណា។
ក៖ ហ្នឹងហើយ!

ខ៖គាត់បានប្រាប់ដំណេលថាពីដើមរឿងមក ប្រាប់ថា កុងហង!
មកលេងផ្ទះនៅឯនេះនោះទេក៏ប៉ុន្តែដល់មក យើញអញអីចឹងទៅ ក៏នាំ
ព្រោះអីគាត់ថា អញស្រលាញ់កូននុងហើយស្អាតណាស់!
អញនាំកូនអញមកដណ្តឹងចឹង ហើយគាត់ប្រាប់ថាគាត់មិនយកនោះទេ
គេនេះពេលនុងគាត់នៅជាមួយនឹងយាយ អត់នៅជាមួយនឹងម្តាយរបស់គាត់
នៅជាមួយនឹងយាយគាត់ យាយគាត់យាយអែម នុងគាត់នៅជាមួយនឹងយាយ។
ក៖ ចាស!
ខ៖ ដល់ពេលដណ្តឹងនោះដណ្តឹងជាមួយនឹងយាយនោះទេ!
កាលម៉ាជំនាន់ប៉ារបស់ខ្ញុំ កាលគាត់ដំណេលប្រាប់ដល់ខ្ញុំហ្នឹង
កាលបានពីជំនាន់ម៉ាជំនាន់លន់ណល់ គេបាញ់ប៉ារបស់ខ្ញុំ
ព្រោះអីប៉ារបស់ខ្ញុំគាត់បានធ្វើខាងអាម៉ារីននុងណាជាទាហានជើងទឹកហ្នឹង
ក៏ប៉ុន្តែពេទ្យ ពេទ្យខាងអាម៉ារីន ក៏ប៉ុន្តែជាទាហានជើងទឹកអាហ្នឹង
គាត់ដំណាលប្រាប់ដល់ខ្ញុំ ថាគាត់កាលពីដើមសកប្រាំង ប៉ារបស់ខ្ញុំនុង
គាត់សកប្រាំង កុំតែគាត់រត់គេញនុង
កុំអីត្រូវដាប់នៅកន្លែងថុកច្រៀវនេះបាត់ទៅហើយ អាហ្នឹងម៉ាក់របស់ខ្ញុំនោះទេ
បានគាត់ដំណាលប្រាប់ថា ប៉ារបស់ហង រកប្រាប់គេត្រង់ថា
បើសិនជាកាលជំនាន់នុង បើសិនជាអ្នកធ្វើការប្រាប់គេអោយត្រង់ៗមក
ថ្ងៃនុងបើសិនជាប្រាប់គេត្រង់នោះគេបានយកទៅរៃចោលនៅកន្លែងថុងច្រៀវនុ
ងបាត់ទៅហើយ តែគាត់ទាញដៃចេញថា ខ្ញុំអឹម! ជាអ្នកនេសាទទេ! ខ្ញុំខាងរៃម៉ង!
កាលនុងសំណាងណា គាត់បានរើសបានម៉ង! បានលឹម៉ងបាន២ត្ឈង! រែក!
ក៏ប៉ុន្តែគេអត់មានបានជឿថាជើងរបស់ប៉ារបស់ខ្ញុំហ្នឹងរកត្រីនោះទេ
ជើងជាអ្នកធ្វើការសកប្រាំង ចឹងមិនខ្ជី? គេអត់ជឿនោះទេ
គាត់ដើរជើងទទេរបាុំងខ្ជើតៗ រែកម៉ង២ត្ឈងហើយរួចទៅ
ទៅធ្វើដាក់ត្រីនៅទន្លេនេះបានត្រីបានអីនុង
រែកទាំងត្រីនិងរែកទាំងម៉ងនុងរួចគេអត់ជឿនោះទេ គេមើលទៅ
ថាដៃជើងជាអ្នកធ្វើការ ហ្នឹងម៉ាក់របស់ខ្ញុំគាត់បានដំណាលប្រាប់ថាចឹងណា។
ក៖ ចាស។
ខ៖ ថាកាលពីគាត់នៅពីក្នេងគាត់មិនបានធ្វើស្រែនោះទេ
ព្រោះអីប៉ារបស់ខ្ញុំជាអ្នកធ្វើការ គាត់បាននិយាយប្រាប់នោះ
ថាសកប្រាំងពេទ្យអាម៉ារីន ជាជើងទឹក កាលម៉ាជំនាន់ពីដើម។
ក៖ គាត់ឈ្មោះអ្វីដែរឱពុកនុង ឱពុកបងស្រីនុងឈ្មោះអី?
ខ៖ ឈ្មោះស្រ៊ុននុងហើយ ហេងស្រ៊ុនហ្នឹង។
ក៖ ហេងស្រ៊ុនហ្នឹង?
ខ៖ ចាស!
ក៖ គាត់ ដល់ពេលចឹងមកបន្តសាច់រឿងរបស់ឱពុកបងស្រីហ្នឹងស្លាប់មូលហេតុអ្វី
ដោយសារអី?
ខ៖ គាត់ស្លាប់ដោយសារ គឺសពង វះពង កាត់ពងម៉ាជំហៀង! កាត់ពង១ចំហៀង
វះបានកាត់បាន៣ខែបានគាត់ស្លាប់។
ក៖ ចឹងគាត់រួចពីរបបលន់ណល់នោះ គាត់បានរួចផុតដែរ?
ខ៖គាត់បានរួចផុត! គាត់បានធ្វើខាងចំការកៅស៊ូនោះខាងសកប្រាំងនុង
នៅខាងចំការកៅស៊ូនោះគាត់មេគេណា គាត់អឺ! ជាមួយនឹងបាវ៉ង
ធ្វើការជាមួយនឹងបាវ៉ងនុងណា។
ក៖ ចាស!
ខ៖ ចាសគាត់បានធ្វើការសកប្រាំងនុងជាមួយនឹងបាវ៉ងដល់ពេលដាច់ទៅ
ដាច់ទៅក៏បាវ៉ងនុងយកយន្តហោះមកយកក្រុមគ្រួសារបងប្អូនម៉ាក់ខ្ញុំនុង
បងប្អូនកូនរបស់គាត់ហើយនិងក្រុមគ្រួសារហ្នឹង យកទៅបាវ៉ងឯណោះ
តែគាត់អត់ទៅនោះទេ ម៉ាក់របស់ខ្ញុំគាត់អត់ទៅនោះទេ

គាត់ថាខ្លាចស្លាប់ម្តងទៀត ក៏អាប្អូនគាត់នុង ប្អូនខាងប៉ារបស់ខ្ញុំក៏សុំ
ថាបើសិនជាហ៊ាងងអត់ទៅ គាត់សុំទៅ យន្តហោះគេមកដល់នៅទឹកចេញ ។
ក៖ អូ!...។
ខ៖ ហ្នឹងគាត់និយាយរឿងកេរប្រាប់ខ្ញុំ គាត់រស់ដល់សព្វថ្ងៃហ្នឹង។
ក៖ ក្រុមគ្រួសាសរខាងឱពុកហេស?
ខ៖ ចាសប្អូន!
ក៖ ប្អូនហ៉!
ខ៖ ចាសប្អូនប៉ាខ្ញុំងាប់!
ក៖ ចឹងគេទៅម៉ាគ្រួសារគេចឹងទៅ?
ខ៖ ទៅម៉ាគ្រួសាររបស់គេរស់នៅដល់រាល់តែថ្ងៃហ្នឹង។
ក៖ នៅប្រទេសអី?
ខ៖ នៅបារាំង! នៅប្រទេសបារាំង
ព្រោះអីចំការកៅស៊ូគាត់បានធ្វើជាមួយនឹងបារាំង
ដល់ពេលនុងបារាំងបានមកហៅ។
ក៖ ចឹងយន្តហោះគេបានមកយកផ្ទាល់តែម្តង!
ខ៖ មកយកផ្ទាល់នេះម៉ាក់របស់ខ្ញុំគាត់បាននិយាយ
គេបានមកយកផ្ទាល់តែគាត់យំបោកខ្លួនអត់ទៅនោះទេ
គាត់ថាខ្លាចកើតម្តងទៀត។
ក៖ ហឹម!
ខ៖ ហើយាកាលម៉ាជំនាន់របស់គាត់នុង គេហៅគាត់ថាសែបៗ លោកសែបនុង!
ក៏ប៉ុន្តែមិនដែរដឹងថាភាសានុងគេមានន័យថាម៉េច?លោកធំ!
ក៖ លោកធំហើយ!
ខ៖ ហ្នឹងហើយ គេហៅថាលោកសែបៗនោះទេ កាលជំនាន់គាត់នុង
ព្រោះអីគាត់រៀនបារាំង សៀវភៅប៉ុណ្ណឹងអី
គាត់ទើបតែបោះចោលពេលគាត់បានស្លាប់នុងនោះទេ សៀវភៅបារាំង។
ក៖ សៀវភៅបារាំងគាត់ច្រើនហេសចឹង?
ខ៖ ហួស! ភាសាបារាំងគាត់ចេះឡើងរិលហ៉!
ក៖ ចឹងបងស្រីងង មានបានដឹងថាតើពេលគាត់នៅរៀននុង
រៀនទៅមានដែរបានចេញទៅក្រៅប្រទេសអីដែស?
ខ៖ គាត់ថាពេលគាត់រៀននុងគាត់បានរៀនចេញទៅក្រៅប្រទេស
រៀនបានចេញទៅក្រៅប្រទេស ដល់ពេលមកពីប្រទេសនុងវិញ
គេបានអោយគាត់ធ្វើកប៉ាលអាម៉ារិន។
ក៖ អូ!
ខ៖ ជំនាន់របស់គាត់និយាយថា កាលជំនាន់សីហនុនៅក្មេង កាលគាត់នៅអាយុ
២០ជាងកាលជំនាន់គាត់អាយុ៣០ កាលជំនាន់សម្តេចសីហនុ ៣០ជាងនោះ។
ក៖ ចាស!
ខ៖ ឡើងគ្រងរាជនោះ!
ក៖ ចាស!
ខ៖ តាំងពីជំនាន់សម្តេចសីហនុនុងគាត់បានរៀននៅប្រទេសគេនុង។
គាត់ប្រាប់ដែរប៉ុន្នានប្រទេសងណោះក៏ប៉ុន្តែខ្ញុំអត់ យកចិត្តទុកដាក់ថា
ត្រាន់តែគាត់ដំណាលប្រាប់ថាចេះចុះមួយចឹង
ក៏ប៉ុន្តែដឹងត្រាន់តែបានចាំថាសម្តេចសីហនុនឹងឡើងគ្រងរាជ្យអាយុ២០ជាង។
ក៖ ចឹងគាត់មានដែរទូន្នានកូនចៅអីដែរ ដូចថាអោយខិតខំប្រឹងរៀនអី
ដូចថាបានបន្តដំណែងអីដូចជាគាត់ដែស?
ខ៖ គាត់បានប្រាប់ថា គាត់មានកូនៗនុង
កូនគាត់ត្មានអ្នកណាគេបានរៀនដល់ស្រុកគេនោះទេ មានតែក្មួយ កូនបងរ
បស់ខ្ញុំនៅងខាងតាប៉ាយងណោះ ខាងសម្បត្តិ។

ក៖ ចឹងហ៉ានុងប្រុសឬក៏ស្រី?
ខ៖ ហ្នឹងហើយ បានក្រៅប្រទេស កូនស្រី អាយុ២០ជាង។
ក៖ ឥឡូវហ្នឹង?
ខ៖ ឥឡូវហ្នឹង!២០ជាង ២៤ទៅ២៥!
ក៖ ចឹងគាត់ជាប់បួកទៅរៀននៅប្រទេសអីគេ?
ខ៖ ទៅរៀននៅប្រទេសស្វីលនោះ១ ទៅប្រទេសកូរ៉េនោះ១
រួចហ្នឹងគេអោយតទៅរៀននៅអាមេរិកនោះទៀត
កាលបោះឆ្នោតនុងសម្តេចហ៊ុនសែនអោយមកសិន
ហើយចាំឡើងទៅរៀនបន្តទៀត ហើយនុងបានឡើងបន្តរៀន
ទៅប្រទេសស្វីសអីគេនោះទេ គេបិនហៅណា
ហើយនិយាយបន្តប្រាប់ដល់ម្តាយមីងនេះ។
ក៖ ចាស
ខ៖
ចឹងសព្វថ្ងៃនេះនៅប្រទេសគេក្មួយហ៉ក៏ប៉ុន្តែវាប្រឡងជាប់ធ្វើការក្រសួងការងារនុ
ងប្រឡងជាប់ហើយវាបានធ្វើខាងក្រសួងការងារនៅប្រទេសខ្មែរយើងហ្នឹងណា។
ក៖ ចាស!
ខ៖ ក៏ប៉ុន្តែវាបានភ្ជួរទៅរៀនទៀត!
ក៖ ចាសបានភ្ជួរទៅរៀនបន្តនៅប្រទេសគេទៀតណ៉!
ខ៖ ហ្នឹងហើយ!អោយមេវានេះទៅ វាបានទៅបន្តរៀននៅប្រទេសគេបណ្ឌិត
វារៀនយកបណ្ឌិតហើយមក រៀនបានបណ្ឌិតនុងបានចប់មកគេអោយ
ធ្វើពេទ្យនៅនេះធ្វើពេទ្យនៅខាងលោកសង្ឆនេះ។
ក៖ អូ! ដល់ពេលរៀនចប់គេបានអោយធ្វើពេទ្យនៅពេទ្យលោកសង្ឆ!
ខ៖ នៅពេទ្យលោកសង្ឆនេះ! អាហ្នឹងលឺវាដំណាលប្រាបដល់ខ្ញុំនេះនោះទេណា។
ក៖ ចាស!
ខ៖ ក៏ប៉ុន្តែវារៀនខាង (២៥:៤៥)
កាលពេលរៀនចប់ទៅតើគេអោយប្រាប់ខែប៉ុន្នាន? ដំបូងគេអោយ៥០០០!
រៀនយកបណ្ឌិតណា វារៀនយកបណ្ឌិតចប់ណា ហ្នឹងវាដំណាលប្រាប់ដល់ខ្ញុំ
វាថាខ្ញុំអាណិតមីងឯងណាស់ ខ្ញុំអាណិតកៅឯងណាស់ ចាំដល់ខ្ញុំរៀនចប់មក
រកបានធ្វើការនៅពេទ្យលោកសង្ឆនុងខ្ញុំចិញ្ចឹមមីង ថាចឹង! យើញមីងឯងវេទនា
វាមកយើញវេទនានឹងភ្នែកណាខ្ញុំចិញ្ចឹមម្ចាយចាស់ ហើយរកវាមិនបាន
ជំពាក់គេនុងយកមកទៅមើលម្តាយ ហើយបើសិនជាយើងលក់មុខរបរប៉ុណ្ណឹងៗ
ត្រាន់តែដោះគេមិនត្រាន់។
ក៖ កាលនុងដីកេរដំណែល ឱពុកម្តាយគាត់មានហេស?
ខ៖មាន!
ក៖ ហើយចឹងបងស្រីគាត់បានមើលថែជំងឺនុងទៅ?
ខ៖ ទាំងអស់អត់មានអោយយើងនោះទេ!
ក៖ ចឹងកូនពៅអត់មានបានកេរ្តឹដំណេលអីនោះទេ ?
ខ៖ អត់មានទាំងអស់ វាលួចដាក់ឈ្មោះវាយកទាំងអស់ អត់មានបាននោះទេ!។
ក៖ ក៏ប៉ុន្តែម្តាយបងស្រីនៅអត់?
ខ៖ ម្តាយនៅ ម្តាយរបស់ខ្ញុំនៅធ្វើការនៅរោងចក្រនៅឯភ្នំពេញនេះ
ដល់ពេលបានមកវាក៏បានលួងឱពុកម្តាយថា អឺម! ម៉ាក់អើយ ប៉ាអើយ!
ខ្ញុំមិនចោលប្អូននោះទេ គង់តែខ្ញុំចែកអោយនោះទេ ដល់ពេលវាដាក់បានឈ្មោះវា
វាអាងយាង ដេញម៉ែឱនេះចេញពីដីនោះទៀតហ៉!
រួចដីនៅកន្លែងផ្ទះនុង២ហិចណាមិនមែនតូចឯណា!
ហើយវាអត់មានអោយនោះទេ។
ក៖ ហើយដល់ពេលផ្ទះនុងគឺផ្ទះគាត់នុងដែរហេស?
ខ៖ ផ្ទះនុងគឺផ្ទះខ្ញុំ!

ក៖ ចឹងជាផ្ទះបងស្រីរកនោះទេហេស?
ខ៖ ចាសផ្ទះខ្ញុំ ៧ ទទឹង៥ បណ្តោយ៧ នៅចោលទាល់តែរាល់ថ្ងៃហ្នឹងគេអោយ
រុះចេញព្រោះអីដីគេ ហើយខ្ញុំខ្ជិលរុះ គឺសុតចិត្តយកប្តីមកនេះទៅ
ហើយក៏បានមកនេះជាមួយនឹងប្តីចឹងទៅ។
ក៖ ចឹងចូលបងនិយាយអំពីប្រវត្តិបងទៅធ្វើនៅរោងចក្រនុងណា
តើមានមូលហេតុអ្វីបានជា បានទៅធ្វើការងារ?
ខ៖ កាលពីដើមមុននុង
កាលបានធ្វើការរោងចក្រនុងខ្ញុំរៀនកាត់ដេរនៅក្នុងស្រុកយើងហ្នឹង
ដល់ពេលរៀនចេះ ស្អីគេ! គេបានមកបង្រៀននឹងយើងអត់យកលុយនោះទេ
អង្គការនុងហ៍!
ក៖ ខាងអង្គការហេស?
ខ៖ ហ្នឹងហើយខាងអង្គការនុង ដល់ពេលរៀនចេះកាត់ម៉ូត
កាត់ច្នៃដោយខ្លួនឯងចឹង ក៏សុំម្តាយនុងអាយុ១៦ទៅ១៧នុង
អាយុ១៧នុងសុំទៅភ្នំពេញ ទៅដេរអាវរយ ម៉ាជំនាន់អាវថៃចូលមក
អាវមីចមអីនុង ។
ក៖ ចាស!
ខ៖ ក៏សុំទៅសុំទៅដេរ កាលនុង១តែ៣០០នោះទេ ១ស្មើនឹង៣០០នោះទេ
អាថ្លៃមួយ៣០០ អាថោក១ ស្មើនឹង២០០ និង១០០! ទៅដេរអាវរយនុង
ដល់រហូតដល់អាយុ១៨ទៅ១៩ បានទៅដេររោងចក្រ
ហើយកាលនុងធ្វើអត់មានសល់លុយនោះទេ ក៏ទៅសុំដេរនៅរោងចក្រ
ហើយប្រាក់ខែបានតែអឺ! ២៥រៀលនោះទេ នៅក្នុង១ខែនោះ
ខ្ញុំធ្វើនុងបានតែ២៥រៀលនោះទេ។
ក៖ អូ! រួចទៅចឹងកាលនុង បានទៅជួលផ្ទះគេឬក៏?
ខ៖ ទៅជួល! ទៅជួលផ្ទះគេ ១បន្ទប់៥រៀល នៅក្នុងនុងគ្នា៧នាក់ ដល់ក្រោយមក
បាន១ឆ្នាំក្រោយមកបានធានាបងស្រីរបស់ខ្ញុំនុងយកទៅ បើក្រពេកទូល
នំបញ្ជាកដើរលក់ ចិញ្ចឹមកូន ប្តីស្លាប់ ហើយមីតូចនោះបាន៣ខែប្តីស្លាប់
ហើយដល់ពេលយើញបងនោះវេទនាក៏បានស្រដោងបងនុង
ទៅចូលនៅរោងចក្រទៀតទៅ ក្រណាស់កាលពីដើមមក ក្ររកស្អីគ្មាននោះទេ
សូម្បីតែអង្គនោះដាក់ដាំបាយក៏រកអីដាក់លាយដែរ ដាក់អង្គបាន១ត្រាប់ៗនោះទេ
ក្រុមគ្រួសារខ្ញុំនុងកំសត់ណាស់ ក្រណាស់ តាំងពីដាច់មកភ្លាម រកស្អីគ្មាននោះទេ
រកអីគ្មានអង្គ ផ្ទះ អីក៏គ្មាននៅនោះដែរ បានច្រកដោយសារតែគេនោះទេ
ដល់បានមកឆ្នាំ៨០ប៉ុន្នាននោះបានមកធ្វើខ្ទមនៅ
បានខ្ទមនៅនុងទទួលបានរហូតដល់ពេលខ្ញុំបានធ្វើការនៅរោងចក្រទៅ
ខ្ញុំយកលុយនុងបានមកធ្វើផ្ទះនៅ បានទទឹងបណ្តាយ ក្បាល៧នុង ។
ក៖ ហឹម។
ខ៖ នុងបានថាជាឈ្មោះដីកេររបស់ខ្ញុំ
ចឹងបានជាខ្ញុំបានជាដីម្តាយឱដាក់យកឈ្មោះទៅហ៍
ដល់ពេលបានឈ្មោះវានុងបានដេញម៉ែឱចេញនុងណា
បានជាខ្ញុំវេទនាមករហូតមកចិញ្ចឹមម្តាយ
ហើយម្តាយក៏អត់ទៅនៅជាមួយនោះដែរ។ខ្ញុំក្រហើយហេតុអ្វីបានជាម្តាយឱមក
នៅជាមួយនឹងខ្ញុំទៀត?
ក៖ គាត់មើលចិត្តយើងចិត្តបាន យើងអាចទីពឹងបាន!
ខ៖ អឹម! ខ្ញុំក្រណាស់ដល់ពេលបានធ្វើនៅរោងចក្រចឹងទៅ បានជាកើតគេដណ្តឹង
គេស្រលាញ់គេដណ្តឹង គេដណ្តឹងច្រើនណាស់ កាលពីដើមមក
បើសិនជាយកថៅកែរោងចក្រខ្ញុំមិនក្រនោះទេ ខ្ញុំកាលពីក្មេង
ខ្ញុំបាននឹកឃើញថា ខ្ញុំក្មេងគេចាស់ ខ្ញុំមិនមិនអាចយកនោះទេ ខ្ញុំអាយុ២០
ហើយថៅកែនោះអាយុ៤០ កាលនុងឆោតណាស់។

ក៖ គាត់កាលនុងស្រលាញ់ជាអនាគតដេស?
ខ៖ស្រលាញ់! ហ្នឹងហើយស្រលាញ់ជាអនាគត់ណា
ដល់ពេលហើយខ្ញុំនាំមិត្តភក្ដីរបស់ខ្ញុំអោយយកទៅ
ហើយគេបានយកមិត្តភក្ដីរបស់ខ្ញុំអោយយកទាល់តែសព្វថ្ងៃហ្នឹងគេបានមានផ្ទះ
នៅផ្សារថ្មីនេះ មុខក៏មិនមើលយើងនោះផង! ។
ក៖ អូ!
ខ៖ ក៏ប៉ុន្តែខ្ញុំនេះថា!
ក៖ ចៅកែនុងជនជាតិខ្មែរយើង?
ខ៖ ជនជាតិអី! ចិន ជនជាតិចិនហុងកុង!
ស្រលាញ់ខ្ញុំណាស់គាត់ហៅខ្ញុំតែអាផណ្ណានោះទេ ថាអាផណ្ណាអើយ!
យកខ្ញុំទៅខ្ញុំទិញផ្ទះ ទិញអីអោយនៅ ហើយខ្ញុំថាខ្ញុំមិនយកនោះទេ អឺ! ចាស់ហើយ
កាលនុងគេនិយាយភាសាអង់គ្លេសណា ដល់ពេលរួចទៅ គាត់ស្រលាញ់ខ្ញុំ
គាត់ថាចរិតហែងនេះឆ្លាតណាស់ បើសិនជានេះអីឆ្លាតរកស៊ីណាស់
បើសិនជាមានដើមនោះហែងឆ្លាតណាស់ ហ្នឹងហើយគាត់មើលដឹង
ដល់ពេលចឹងទៅខ្ញុំអត់យក សានចាស់!
បើសិនជាពេលនុងម៉េចយកទៅ២០និងអាយុ៤០នុង ខ្ញុំគ្មានលំបាកដល់នឹង
ខ្ញុំប្រាប់អ្នកគ្រូឯង ដល់ពេលអត់យកទៅវេទនារហូតមក កំសត់រហូតមក
រួចចិញ្ចឹមឪពុកម្ដាយមក
ហើយបងៗគេអត់គិតគូចិញ្ចឹមតាំងពីក្មេងមកដល់ពេលក្រមុំ
ហើយកាលនុងគាត់អត់មានមកនៅពេលដែលបានប្ដីហើយអត់មានបានកប
នោះទៀត មានកូនហើយ គេមានស្រីមានអី បានកើតកូនបាន៥ខែ
បីកូនរត់ចោល ព្រោះអីវាអត់មានដែរអោយលុយយើងកើតកូនតែម្នាក់ឯង។
ក៖ ចឹងមានប្ដីនុង គេចូលស្ដីដណ្ដឹងយើង?
ខ៖ គេចូលស្ដីដណ្ដឹងត្រឹមត្រូវ ! ការត្រឹមត្រូវ នោះរូបថតមានមកដល់ពេលឥឡូវ។
ក៖ កាលការនុងនៅក្នុងភូមិ?
ខ៖ នៅក្នុងភូមិរបស់ខ្ញុំនុង! កាលនុងប្រកាប់បាន៥០ម៉ឺន។
ក៖ ស្រុកកំណើតរបស់គាត់នៅឯណាដែរ?
ខ៖ ស្រុកកំណើតរបស់គាត់នៅឯខាងណាមគិន។
ក៖ ចាស។
ខ៖ ស្រុកកំណើតនៅណាមគិន។
ក៖ ហើយមកដល់ពេលឥឡូវនេះគាត់នៅរស់ដែរហ៎?
ខ៖ ឥឡូវនៅរស់ហ្នឹង តែគេបានយកប្រពន្ធ១នាក់ទៀតនៅឯភ្នំពេញនោះ
អត់មានមកនោះទេ។
ក៖ ហឹម
ហើយដល់ពេលឥឡូវនេះហ្នឹងបងស្រីដល់ពេលចឹងទៅកាលនុងបានបែកពីប្ដីនុង
នៅទំងន់ប៉ុន្មានខែ?
ខ៖ អឺ! ទំងន់! អត់នោះទេ កាលបែកពីប្ដីនុងកើតបាន៥ខែហើយ។
ក៖ បានកូន៥ខែហើយហ៎?
ខ៖ ចាសកើតបាន៥ខែហើយបីកូនរត់ចោលតែម្ដងទៅ
បើសិនជាលុយវាអត់អោយ ផ្ទៃផ្ទះក៏វាអត់អោយ ហើយយើងនេះវាកូនខ្ចី ។
ក៖ ចឹងកាលនុងនៅភ្នំពេញទេហ៎?
ខ៖ ចាសកាលនុងយើងនៅឯភ្នំពេញ! កាលនុងយើងកូនខ្ចីចឹង
តើយើងទៅរកឯណាកើត?
ក៖ អូចឹង មានន័យថាកាលការរួចហើយទៅភ្នំពេញ?
ខ៖ ទៅរកស៊ីនៅភ្នំពេញ!
ក៖ ទៅរកអី?
ខ៖ ទៅធ្វើការរោងចក្រ!

ក៖ ចឹងទៅធ្វើការងាររោងចក្រដ៏ដែរ?
ខ៖ ចាសទៅធ្វើការងារនៅរោងចក្រដ៏ដែរ។
ក៖ ចឹងចុះគ្រួសារបងស្រី?
ខ៖ គ្រួសាររបស់ខ្ញុំធ្វើជាជាងម៉ូតូ! វាធ្វើៗទៅវាមានស្រី ដូចថាយើញថាក្រអីចឹងទៅ
កាលមិនទាន់យកប្តីនោះខ្ញុំសល់លុយដែរ ប្តីនុងក្រនោះទេ
ដល់ពេលបានយើងមានលុយធ្វើដើមរកស៊ីចឹងទៅវាបែកឆ្វេងទៅមានទៀតទៅ
បានជាខ្ញុំនេះធ្លាក់ខ្លួនមករហូត!។
ក៖ បីកូន៥ខែនុងចេញមកស្រុកកំណើត?
ខ៖ ចេញមកស្រុកកំណើតផ្ទើអោយម្តាយមើលចឹងទៅយើងនេះទៅធ្វើការវិញ
អោយបៅទឹកដោះគោ។
ក៖ធ្វើការនៅរោងចក្រណ៉!
ខ៖ ចាសធ្វើការរោងចក្រវិញ បៅទឹកដោះគោ! រូបថតនៅដល់ពេលសព្វថ្ងៃ
ដាក់បៅទឹកដោះគោ រូបថតការ ដល់ពេលអោយកូនបៅទឹកដោះគោចឹងទៅ
បាន៣ឆ្នាំសូមជុំវិញខ្ញុំអត់យក វាធ្វើបាបពេក ធ្វើបាបចិត្ត ធ្វើបាបចិត្តណាស់
អ្នកគ្រូអើយវេទនាណាស់ខ្ញុំ ។
ក៖ ហើយដល់ពេលកូនរបស់បងស្រី ?
ខ៖អាយុ១៨ហើយ អាយុបាន១៩ឆ្នាំ២០០១។
ក៖ គាត់ធ្វើអ្វី?
ខ៖ ឈ្មោះអ៊ី! ហ៉ន ម៉ែងគៀង។
ក៖ គាត់កើតនៅថ្ងៃខែ?
ខ៖ កើតនៅខែ១ ថ្ងៃ២២ ថ្ងៃអង្គារ! រួចទៅ ២០០១។
ក៖ ២០០១ណ៉! ហ្នឹងហើយ!
ខ៖ ចាស!
ក៖ ចឹងកូននុងស្រីឬក៏ប្រុស?
ខ៖ កូនប្រុស!
ក៖ អូ! មកដល់ពេលឥឡូវនេះគាត់នៅរៀនឬក៏?
ខ៖ ឈប់រៀនហើយបានប្រឡងត្រឹមថ្នាក់ទី១២បានឈប់រៀនតែម្តង។
ក៖ អូ!
ខ៖ ឈប់ទៅបានមកធ្វើការនៅការវ៉ាសសុំងនៅឯភ្នំពេញនុង
ដល់ពេលបានមកធ្វើការលំបាកពេកក៏ឥឡូវនេះឈប់ទៀតហើយ
បានទៅធ្វើតេសនៅឯខាងរោងចក្រទៀតហើយ។
ក៖ អូ! កូននុងនៅជាមួយពីណា?
ខ៖ កូននុងនៅជាមួយនឹងអ៊ីវាក៏ប៉ុន្តែទៅមកៗមកហ្នឹង។
ក៖ មកហ្នឹងដែរ?
ខ៖ចា! មកទៅមកហ្នឹង
បានសុំធ្វើការនៅរោងចក្របានហើយបានមកដេកនៅឯនេះ។
ក៖ រួចទៅប្តីបងស្រីក្រោយហ្នឹងមានថាអីដេស?
ខ៖ គាត់អត់មានថាអីទេ!
ក៖ អត់ថាអីទេអ៉!
ខ៖ បើកូនរបស់ខ្ញុំហៅប៉ា ហើយគាត់អាណិតចឹងណា ខ្លាចតែអាផ្លូវ១នុង
ចេះតែប្រដៅវា កុំអោយទៅអាផ្លូវ១ហ្នឹង ចេះតែប្រដៅអោយវារកស៊ីទៅ
កុំអោយវាទៅអាផ្លូវ១នុង ចេះប្រាប់ទៅ បើជាប់ទៅគ្មានលុយដោះនោះទេ
រួចវាប្រាប់ខ្ញុំថា ខ្ញុំនិយាយប្រាប់ម៉ែឯងតាមត្រង់ខ្ញុំអត់មានប្រព្រឹត្តិទេ
អាផ្លូវនុងហ៉ ខ្ញុំខ្លាចណាស់ ខ្ញុំអត់ហ៊ានប្រព្រឹត្តិនោះទេ
តែខ្ញុំចេះតែបង្ហាបវាខ្លាចវាទៅអាផ្លូវនុង។
ក៖ ចាសហ្នឹងហើយនិយាយប្រាប់វាបន្ថែមទៀតទៅ!
ខ៖ ចាស!

ក៖អោយគេចេះចាំ!
ខ៖ កូនវាវេទនាណាស់! កូនអាយុ២០០១ តើអាយុ១៩ឬក៏១៨? កើតឆ្នាំ២០០១!
កាល២០០១នុងខ្ញុំអាយុ២៩កើតកូននុងអាយុ២៩ កាល២០០១
ហើយខ្ញុំមេម៉ាយអាយុ២៩ដែរនុង ទាល់តែខ្ញុំអាយុ៥០ ដល់ពេលម្តាយបានស្លាប់ទៅ
អត់មានម្តាយអត់មានដីផ្ទះនៅនុងហើយក៏កើតជាយកប្តីទៅ ។
ក៖ ក៏ប៉ុន្តែកាលពីមុនដំបូងបងស្រីនេះដេស
?ដូចជាលំបាកកាលពីមុនដំបូងនុងនៅក្នុងចិត្តនុងដូចថា
បើសិនជាមានគេស្តីដណ្តឹងអីយកដេស?
ខ៖ យក!
ក៖ យកហ៉!
ខ៖ យកបើសិនជាយើងលំបាក ខ្ញុំនឹកត្រង់ថា
បើសិនជាយើងលំបាកហើយយកគេជាអ្នកគួសមទៅ
បើសិនជាយើងវាអត់ចឹងមិនបានអីអោយគេបានម៉ារកស៊ីមានដីចុះ
គ្មានទ្រព្យសម្បត្តិអីចឹងមានដីអោយគេដាំដំណាំដំណោចអីចឹង
គឺថានៅក្នុងចិត្តនេះបានគិតចឹងណា។
ក៖ ចាស!
ខ៖ នៅក្នុងចិត្តនេះបានគិតចឹង គឺបានគិតថាបើសិនជាយើងនេះគ្មានដី
គ្មានលុយ គ្មានកាកអីចឹង គ្មានទ្រព្យសម្បត្តិអីនោះទេ មានត្រឹមដីហ្នឹង
ហើយចឹងអោយបានដាំដំណាំដំណោចនុងអោយបានរកស៊ីចឹងទៅ
ខ្ញុំមកនុងគឺខ្ញុំក៏បានប្រាប់គេដែរ ថាខ្ញុំមិនចង់បានរកស៊ីអីម្នាក់ឯងនោះទេ
ខ្ញុំសុំតែសំរាប់ស្លាប់ទៅវិញ។
បើសិនជាអោយខ្ញុំដណ្តើមកេររបស់អ្នកឯងនោះខ្ញុំអត់មានដណ្តើមនោះទេ
បើសិនជាអ្នកឯងអោយក៏អោយទៅ បើសិនជាអ្នកឯងមិនអោយនោះក៏អត់ទៅ
ក៏ប៉ុន្តែត្រាន់តែថា ផ្ទើសំរាប់ស្លាប់ទៅវិញ
ព្រោះអីទោះបីជាស្លាប់យកទ្រព្យសម្បត្តិទៅមិនរួចនោះទេ
ចឹងខ្ញុំសូមតែម៉ារស់ហើយនិងស្លាប់ទៅវិញ ។
ក៖ អូ!
ខ៖ ខ្ញុំបាននិយាយប្រាប់ដល់កូន១ថាចឹង!
ក៖ ឥឡូវនេះចឹងសូមបងរំលឹកអំពីអតិតកាលពីជីវិតរបស់បងដែរមានការតស៊ូ
តាំងពីកាលពីក្មេងមក តើបងមានជីវ:ប្រវត្តិរបស់បងកាលពីក្មេងមក?
ខ៖ កាលពីក្មេងមកតាំងពីអាយុ១៣ឆ្នាំ!
ក៖ ចេះ?
ខ៖ ចេះរកស៊ី ចេះទៅរាវលៀស នៅបឹង បឹងនុងឆ្ងាយណាស់ ដើរពីហ្នឹងទៅណ៉
ហួសទួលតាកោលទៀតណ៉ បឹងនុងទៅរាវលៀសនុងទូលមក ។
ក៖ ប្រហែលជា៥គីឡូដីអីដេស?
ខ៖ មិនដឹងថាប៉ុន្នាននោះទេ មិនមែន៥នោះទេ ចូល២០គីឡូអីជាងហ៉!។
ក៖ ចឹងចេញមកស្មាណា?
ខ៖ ចេញពីផ្ទះមក ម៉ោង៤កន្លះ! មកដល់បឹងម៉ោង៧។
ក៖ ឆ្ងាយ! ណាស់! ចឹងការធ្វើដំណើរកាលនុងដើររហូត?
ខ៖ ដើររហូត! អាយុ១៣នុង ហើយដល់ពេលថ្ងៃអាទិត្យនុងបានទៅរាវលៀសហើយ។
ក៖ អូ!
ខ៖ បានលៀសមកប្រលក់អំបិល ទូលដើរលក់ ដើរលក់នៅតាមផ្ទះឆ្ងាយណាស់
ដើរពីផ្ទះនុងចេញពីផ្ទះមកដល់កន្លែងលក់នុង៥គីឡូដី ឡើងវាល! ។
ក៖ ឆ្ងាយពេក!
ខ៖ មកនុង ដល់ពេលកំសត់ពេក ចង់លក់ដាច់ មុនគេភរ គេថា៖
លៀសអោយលៀស! ជួយទិញខ្ញុំទៅ ខ្ញុំក្រ ខ្ញុំអត់មានឱពុកម្តាយទេ ខ្ញុំកំព្រា។
គេលឺថាកូនកំព្រា អាយុ១៣ គេអាណិត គេជួយទិញម្នាក់៣កំប៉ុង ១២កំប៉ុង

អោយស្រាលស្អី រួចហើយបាន១ខែ ផ្ទះគេនុងមាន គេមានផ្ទះនុងធំណាស់
ផ្ទះរបស់គាត់នុងគឺ២ខ្នង ហើយគេអត់មានកូនស្រីនោះទេ
គេបានសួរថាអត់មានឪពុកម្តាយមែនហេស? ខ្ញុំថាអត់មាននោះទេ!
ហើយគេបានថាអូ ក្មេងស្អាតដំហើយ ហើយចឹងតើហែងនៅជាមួយនឹងអ្នកណា?
ហើយខ្ញុំថានៅជាមួយនឹងបងស្រី! ។ចឹងបានមកដល់បងស្រី
ហើយអោយគាត់ប៉ុន្ទានដំឡឹងទេ កាលនុងហ៎ គាត់សុំទិញខ្ញុំប៉ុន្ទានដំឡឹងនោះណ៎
ថាយកកូននុងអោយទៅបណ្តុះបណ្តាយរៀន មើលទៅកូននុងស្លាតណាស់
តែបងស្រីរបស់ខ្ញុំនុង ដេញវ៉ៃ ថាទៅការគេថាអត់ម្តាយឪយ៉ាងម៉េចហង?
តើឃើញម៉ែឪក្រហេសហង? គេសុំទិញប៉ុន្ទានដំឡឹងហ៎
ខ្ញុំកាលនៅពីក្មេងនោះស្អាតណាស់ គេសុំទិញ។
ក៖ អូ! សក់រ៉ែង!
ខ៖ សក់រ៉ែងឡើងហៀលចង្កេះនោះ! អ្នកណាគេក៏គេស្រលាញ់នោះដែរ
ដល់ពេលពេញរូបពេញរាងអ្នកគ្រូអើយ គឺថាគេដណ្តឹងមិនបាន
គេដណ្តឹងកើតជាអាផ្ទ្ធ ១ងដ៏តមើលមិនឃើញនោះទៅជាឆ្ងូត ដើរលេរលូ
ចេះមើលលោកទាន់ ណាបាន បានជា បានរស់មកទាល់តែរាល់ថ្ងៃ
កាលនុងស្អាត់មែនទែនណា ខ្ញុំមិនអ្ហ៊ីតនោះទេ។
ក៖ ចាស! អូ!
ខ្ញុំចង់អោយបងនិយាយអំពីដំណើរជីវិតរបស់បងកាលពីក្មេងនុងមកម៉េចទៀត
ណ៎ បងឯងចង់ចាំដែស?
ខ៖ ហើយដល់ពេលរួចមកទៀត រៀនដល់ពេលថ្ងៃអាទិត្យទៅទៀតហើយ។
ក៖ រៀន!
ខ៖ រៀន អោយតែដល់ថ្ងៃអាទិត្យឈប់ទៅទៀតហើយ!
រួចដល់ពេលម៉ាក់ខ្ញុំអត់អោយទៅនោះទេ គាត់ថា៖ កុំទៅណា នៅជួយវ៉ែកួមអញ
ក៏ទៅ។ លួចដាំបាយ អ្នកគ្រូអើយ ដាក់ដាំបាយផ្ទ្ធិន ម៉ីពួកម៉ាក់មកហៅថា
អើយពៅ!? ចាស! កុំមាត់លីពេកម៉ាក់ឯងអត់អោយទៅនោះទេ!។
មកដាក់តែស្អីមកអញអោយបាយស៊ី!
លួចរត់។ដល់ចឹងម៉ាក់ខ្ញុំតាមវ៉ែជិតដល់បឹងនោះ ថានៅតែបន្ទ្ធិចទៀត
ថានៅប្រហែលជាពីត្រឹមហ្ន្ធឹងអ៊ីហ្ន្ធសវត្តពោធិសាលានុងទៀត
គាត់បានបកមកវិញ គាត់ខ្ជិល ថាទៅ បណ្តោយទៅ ដេញវ៉ៃវាមិនឈប់! រត់!!
ទៅស៊ីបាយដោយសារគេ នៅទឹកបឹងនុង! អ្នកគ្រូអើយ រាយឡើងពេញស្អីមុនគេ
និយាយថាពីឆ្ងាកណាស់ រាយដាក់អញ្ជេញ១ហ្ន្ធឹង រាយដាក់ជើងមួយកាយ៉ែងហើយ
ដល់ពេលរ៉ែងហើយបានមកយកលាងទឹកអោយស្អាតទៅ រ៉ែស១ត្រាប់!ៗ
ដាក់ផ្ទ្ធ ក់ក្រមាចែ ដាក់ចង់ក ដាក់នៅចង្កេះនេះ
ដល់ពេលលាងហើយដាក់តាមហ្ន្ធឹង ដាក់ចឹង លាងរួចហើយដាក់នៅត្រឹមហ្ន្ធឹងទៅ។
ក៖ ចាស។
ខ៖ ហើយទៅលុក ដាក់រ៉ែកទៀតទៅ លុកដាក់ត្រឹមហ្ន្ធឹងទៅ ងូតរ៉ែកដាក់ទៀតទៅ!
ពេញ១ផ្ទ្ធ ក់ក្រមាបានប៉ុណ្ណ្ធឹងក៏បានយកទៅចាក់ដាក់នៅក្រមាបាន១ដង!
ចាក់ស្អីបាន១ដង នោះគឺប្រហុកវិញគឺបានស៊ីតែត្រួយរ៉ាងនោះទេ
អត់មានដាយស៊ីនោះទេ មានតែត្រួយរ៉ាង
ដល់ពេលមកវិញអស់មានបាយកកស៊ីឡើងប៉ះអ៊ំពិលអ៊ី អើយ!
កាលនុងគេអត់ឈប់ឈប់ ទូលលៀសអត់រួចយ៉ !!
ហើយទៅអត់ហ៊ានចូលផ្ទះនោះទេ ម៉ាក់រ៉ៃ ហើយដល់ពេលរួចទៅ
ទៅនៅផ្ទះបងណ៎ ផ្ទះបងនៅឯខ្ជ ល់ឯណោះ នៅឯខាងពាមក្ជងនេះ
អត់មានហ៊ានទៅផ្ទះនោះទេ ហើយបើសិនជាតែមកម៉ាក់រ៉ៃ ចឹងនៅឯនុង ហាល
លៀសនៅឯនុង ដល់ពេលវ៉ាស្ជ ត បាន២ថ្ងៃបានមកផ្ទះ ។
ក៖ ចឹងលក់បានលុយហើយបានមកផ្ទះ?

ខៈ បានលុយ! បានប៉ុន្មានកាកនោះទេ! ១កំប៉ុង បាន៥កាក!
រួចបានលុយពីនុងបានប៉ុន្មានពាន់នោះទេ បាន៣០០០
បាន១កំប៉ុង៥កាកនុងបាន៣០០០ ដល់បាន៣០០០ច្រើនដល់មកផ្ទះ
ម្តាយលែងរ៉ៃហើយ បានលុយអោយគាត់២០០០
ហើយទុក១០០០ទិញស្ករគ្រាប់ទៅលក់នៅសាលារៀន! ។
កៈ ហឹម។
ខៈ ១គ្រាប់១សេន អាកាកសេននោះ! លក់លួចលក់នៅក្នុងសាលារៀននុង។
រួចដល់ពេលក្រមែនទែនអ្នកគ្រូអើយ! រកលុយទៅរៀនមិនបានខឹងគ្រូរៀន
សុំឈប់មិនបាននោះទេ អត់ឈប់
នោះទេ រៀន ទៅថ្ងៃ១លួចកាច់ស្វៃ! កាច់អាផ្លែស្វៃយកទៅដាក់តុគ្រូចែក
ដើម្បីថាអោយគ្រូនៅថ្ងៃហ្នឹងអត់រៀនអាង នឹងទៅរកលៀស។
កៈ ហាស១!អឺ!
ខៈ អឺ! ហើយដល់ពេលគ្រូអង្គុយនឹងតុនុងរមួសស្វៃចឹងទៅ
ក៏ប្រាប់កូនសិស្សនុងថា ថ្ងៃហ្នឹងយើងអត់បានរៀននោះទេ យើងសំរាក។ អូ!
អរណាស់! បានទៅឡើងអំពិល ទៅប៉េះអំពិលយកលក់ ទៅស្លៀកសំពត់ កៅស៊ូនុង
យកទៅលក់ អាយុបាន១៣ទៅ១៧នុង។
កៈ ចាស ហើយរួចទៅអំពិលនុងប៉េះបានដែរ បានជាយ៉ាងម៉េច?
ខៈ លក់បាន! ចឹងទៅយកលុយនុងទុកស៊ីទៅរៀន លែងសុំម៉ាក់ហើយ។
កៈ ចាស!
ខៈ ព្រោះអីខ្លាចម៉ាក់ប្រើអោយរ៉ៃក្អម គាត់រ៉ៃក្អមផង រ៉ៃស្ករផង រ៉ៃឆ្នាំងផង
រួចមុននឹងរ៉ៃ ក្អមកាលមុនដំបូងគេមិនទាន់រ៉ៃគេបញ្ឈរដូចជាថុងចែក។
កៈ ចាស។
ខៈចឹងបង្វិលមាត់ចឹង! ដាក់ក្រណាត់មកបង្វិលមាត់ចឹងដើរជុំវិញវិលទៅ
មាត់នុងអោយស្អាតទៅ ដាក់បញ្ឈរដូចជាថុងចឹង
រួចទៅដល់ពេលរឹងទៅបានយកមករ៉ៃអោយឡើងក្អេង រ៉ៃអោយឡើងក្អេងចឹងទៅ
ដល់ពេលរាងស្រពប រករ៉ៃមកជិតក្តិតបានហើយ រ៉ៃវាបញ្ចិតក្តិតចឹង អាហ្នឹងក្អម
ហើយថាខ្ញុំលលាតសារ៉ុង រ៉ៃក្អម លួចរត់ទៅប៉េះអំពិល អានុងស្រួលចង់ក្បិន
ស្រួលឡើង រួចទៅខ្មៀលគោទៅ ដាក់បាយទៅឃ្វាលគោ ហើយជិះនៅលើខ្នងគោ
ហើយគោវាផ្អើរ ចេញពីដើមអំពិលនុង ធ្លាក់ពីខ្នងគោនុងទៀត រួច
ហើយទាល់តែដល់កន្លែងមើលគោ ប្រវត្តិរបស់ខ្ញុំអំពិល បានដាំ៥រង់មួយនាក់!
ហើយកាលនុងបានតែពីសាច់ពីដីនេះមកនោះទេ
រួចហើយបងខ្ញុំនេះគេបានដាំពីដីនុងមកបានប៉ុនេះ
ហើយលួចកាច់ពីអំពៅនុងគេនុង យកទៅស៊ីនៅឡៅជិះនៅលើខ្នងគោ
ហើយអាគោនុងផ្អើស្លឹកអំពៅ ធ្លាក់ឯងនៅកណ្តាលស្រែឡើងលឺតែផឹង!
ផ្អើអាដែង! ខ្វាយទឹកលឺខុល!។
កៈ អូ!
ខៈ ហឹម! ប្រវត្តិរបស់ខ្ញុំប៉េះអំពិល រកក្តាម ប៉េះម្អម យក។
កៈចឹងចង់ចឹងថាប៉េះក្តាមនុងយ៉ាងម៉េច?
ខៈ កាលនុងចាប់នៅរន្ធរបស់វា ហ្នឹងហើយដូចថារន្ធនឹងវាចឹងទឹកវាលិច
ចឹងមានទឹកពពុះៗ។
កៈ ចាស។
ខៈ ដូចពពុះបាយចឹងណា ហើយយើងកាយអត់អោយមានពពុះនុងទៅ
យើងដកចឹងណា! ថាទិតុយៗ!ហាសៗ។
គៈ (ក្មេងនៅជិតនុងសើច! ហាសៗ!)
ខៈ ដកចឹងហើយអោយក្តាមនុងចេញ ថាៈ ទិតុយៗ!
គៈ ហាសៗ។
ខៈ ទិតុយៗ។

ក៏ ដល់ពេលចឹងលីសំលេងយើងចឹងមក ក្តាមនុងចេញ?
ខ៏ ចេញ!
ក៏ ក្តាមនុងលីសំលេងចឹងចេញ?
ខ៏ ហ្នឹងហើយលីសំលេងនុងចេញ!
ក៏ ដល់ពេលចេញមក ដល់ពេលតែចេញក្រៅរន្ធចាប់ដាក់ថុង
អោយតែចេញមកចាប់ដាក់ថុង។
ក៏ ចឹងពីវិធីដែរនេះនុង អោយក្តាមនុងចេញពីក្នុងរន្ធនុង
តើចេះដោយខ្លួនឯងឬក៏ម្តាយប្រាប់?
ខ៏ អត់!ទេ! ចេះខ្លួនឯងតែម្តង
ដល់ពេលហើយចេះតែស្រែដោយខ្លួនឯងចឹងតែម្តងថាទីតុយ! ។
ក៏ ហាសៗ!
ខ៏ ដល់ពេលដកសុបចឹងទៅ វាចេញតាមដៃរបស់យើង
ចេញវាលមកចាប់ដាក់ថុង រួចបានក្តាមនិងបានទាំងត្រី! ហើយមានឆ្នៀង ជាត!
ព្រោះអីកាលនុងអត់មានលុយទិញត្រីស៊ីនោះទេ កាលនុងសំបូរត្រីណា
នៅតាមស្រែ នោះ ចឹងហ្នឹងហើយយកឆ្នៀងនុងជាតហើយ។
ក៏ ចាស!
ខ៏ ខ្ញុំជាត បានត្រីការតេសឡង់ បានក្តាមបានត្រីក្រាញ់ បានកូនស្រីផ្ទួក
បានឡើងប៉ុណ្ណឹងៗ! យកមកចំហ៊ុយ ត្រួយអង្ការដីរបស់យើងនោះ ហ្នឹងហើយ
នឹងខួរក្តាមហ្នឹង ដាក់ត្រួយអង្ការដីនុងមកនឹងក្តាមយកដាក់ស្ទាំងទៅ
យកដាក់ចំហ៊ុយខួរក្តាម ប៉ុនៗហ្នឹង
ដល់ពេលហើយវាឆ្ងិនទាំងក្តាមនឹងត្រួយអង្ការដីនុង ហើយចាក់ទឹកខ្ទេះ
ហើយខួរក្តាមនុងយកមកចំហ៊ុយជាមួយនឹងខួរក្តាមឡើងប៉ុនៗនេះ ។
ក៏ ចាស។
ខ៏ រួចទៅចាក់ទឹកខ្ទេះចឹងទៅ យកអាត្រួយអង្ការដីនុង មកចុច
ទឹកខ្ទេះនុងច្រលក់ហើយស៊ីៗ ស៊ីជាមួយនឹងបាយនុង
ហូបជាមួយនឹងបាយនុងវាឆ្អែតទៅ
នឹងមានជាមួយនឹងក្តាមត្រាំនុង១មុខទៀតទៅ ហ្នឹងម៉ារ៉ីកជាតត្រីនុង
ហើយអាកាតេសឡង់នុងលីង
ជាតអាការតេសឡង់នុងនិយាយថាឆ្លើងឡើងប៉ុនៗនេះ ឡើងសន្លាក់
អាឆ្លើងហ្នឹង ឡើងដូចកង់ជើងយើងចឹង។
ក៏ រួចទៅបងស្រីខ្លាចអត់ឆ្លើងនុង?
ខ៏ អត់នោះទេ!កាលពីមុនដំបូងខ្លាច ដល់ម៉ាក់ខ្ញុំថា៖ កូនអើយ!
អាហ្នឹងសត្វនៅលុងទឹកវាចឹងហើយ វាលុងទឹកវាស្រវ៉ែលស្រវ៉ាលគោងចឹង
ដូចជាម៉ារ៉ាមដៃចឹង យកអាកៅស៊ូកងនុងចង់នៅជើងចឹងទៅក៏ចុះទៅ
ឡើងផ្ទក!ចឹងទៅ ដូចជាមារ៉ាមដៃចឹងខាងនេះចចឹង
ចាប់មកគឺចាប់វ៉ាហ៊ែកមាត់! កាលពីមុនដំបូងនោះខ្លាច
តែដល់ពេលគាត់បាននិយាយចឹងទៅលែងខ្លាចហើយ ចាប់មក ប៉ះប៉ាត!
ឈាមចេញហូរចឹង ហើយចាប់ហ៊ែកមាត់
ដល់ពេលចាប់មាត់ហ៊ែកមិនបានយកអាបន្ទ្លាក្រសាំង
ដោតខាងនេះ១ខាងនោះ១ទាញ មាត់វ៉ាថា៖ ហ៊ែងពូកែកៀមអញហ៊ែង!។
តែកាលពីមុនដំបូងខ្លាចឡើងញ័រចឹង តែដល់ពេលម្តាយការថា៖
អាហ្នឹងសត្វលង់ទឹកកូនអើយ!។
និយាយថាអាកាតេសឡង់!បាន១ឆ្នៀងមកបាន១ក្ញែង ។
ក៏ អូ!
ខ៏ ដល់ពេលត្រីក្រាញ់នោះក៏ចឹងដែរ ដល់ពេល១ឆ្នៀងមក គឺបានចង់១ក្ញែង។
ក៏ សំបូរណាស់កាលនុង!

ខ៖ យកមកដាក់លីងហើយកាលនុងបងប្រុសខ្ញុំបងបូរនេះគាត់
រកកង្កែបនៅពេលមេយធ្លាក់ភ្លៀងចឹង ដូចមិញចឹងណា
ធ្លាក់ភ្លៀងនៅពេលយំណាចឹងដើរឆ្លុះកង្កែប នៅ១យប់៥០គីឡកង្កែប។
ក៖ អូ!
ខ៖ ៥០គីឡ ដល់យកមក បាន១៥០គីឡ ពន្លាតទៅ កាត់ក្បាលទៅ ពន្លាតទៅ
យកសាច់យកទៅលក់នៅកំពង់ចាម ១គីឡ២៥០០
កាលម៉ាជំនាន់នុងដល់ពេលមកវិញ បានទិញអង្ករបាន២ទៅ៣គីឡទៅមកវិញ
នំអីអោយប្អូនអីបានបន្ថិចមក អោយមានកំលាំងជួយពន្លាត
ហើយយកពង្ងក់ដើរទៅហើយ ត្រាប់ចឹងទៅ នៅក្នុង១ថ្ងៃចឹងទៅ
បាន២០គីឡអីចឹងទៅ កាលនុងបងរបស់ខ្ញុំរកស៊ីចិញ្ចឹមប្អូននុង។
ក៖ ប៉ុន្តែកាលនុងទៅ មានល្មក់អីជិះទៅ?
ខ៖ កង់!
ក៖ ជិះកង់ទៅលក់នោះទេ?
ខ៖ កង់ជិះកង់ទៅលក់ដល់កំពង់ចាមនុង! ក្រោកឡើងពីម៉ោងពាទៅ។
ក៖ អូ!
ខ៖ ក្រោកឡើងតាំងពីម៉ោងពាទៅជិះកង់
រួចកង្កែបម្នាក់បាន៥០ទៅ១៥០គីឡយកទៅលក់នៅកំពង់ចាម
ដល់ពេលយកទៅលក់នៅកំពង់ចាមនោះអត់ដាច់ យកទៅលក់នៅបូសខ្នោ! ។
ក៖ ហឹម!
ខ៖ រួចដល់ ថាប្រវត្តិម៉ាក្រុមគ្រួសារបស់ខ្ញុំនោះក្រមែនទែន រួចទៅបាយណា
អង្ករដាំលាយជាមួយនឹងត្រកួននោះក៏មានដែរ លាយជាមួយនឹងត្រកួនផ្លែចេក
ដើរសព្វចឹងបានថា ពីខ្ញុំអាយុដល់១៥ឆ្នាំ នៅរត់មុជទឹកដើរស្រាច
នៅលេងទឹកភ្លៀងនៅឡើយនោះទេណា
ម៉ាជំនាន់ខ្ញុំគ្មានអ្នកណាគេចេះស្រលាញ់ៗអីនោះទេ
គឺវាលរត់លេងតែទឹកភ្លៀងតែម្តងនៅអាយុ១៥។
ក៖ ហឹម។
ខ៖ ចឹងបានថាអាហ្នឹងមកពីដំរិះរបស់ខ្ញុំទេ អ្នកគ្រូអើយ!
បើសិនជានិយាយទៅមកពីដំរិះម្តាយរបស់ខ្ញុំគាត់ស្រលាញ់ខ្ញុំពេក
ដូចថាប្អូនគាត់ដែរទៅបាវាំងនុង គាត់សុំខ្ញុំ គាត់សុំមីពៅនុងថា៖ អាហៀ។
អោយខ្ញុំសុំមីពៅនុងយកទៅនៅបាវាំងមក! គាត់ថាគាត់មិនអោយនោះទេ!
បើសិនជាមីទី៤ មីទី៥យកទៅនោះទេ អញមិនអោយនោះទេ ហើយគាត់ថា៖
គាត់មិនយកនោះទេ មីទី៤អត់ស្អាតនោះ ហើយបើសិនជាយកគឺយកមីទី៥។
កុំអីខ្ញុំត្រូវសំណាងទៅនៅប្រទេសគេហ៍ ក៏ប៉ុន្តែមកពីម្តាយឱរបស់ខ្ញុំនុង
គាត់មិនអោយគេ គាត់ចង់អោយកូននៅកម្មចឹង ។ ខ្ញុំត្រូវសំណាង២ដង
សំណាងចឹកយកទៅនៅបាវាំងនោះ១ សំណាងបានប្តីថៅកែនោះ១
ប៉ុន្តែមិនដឹងជាយ៉ាងម៉េចឈាមអត់អណ្តែក វានៅតែវេទនា
ប៉ុន្តែដល់ពេលមកដល់ពេលបច្ចប្បន្ទនេះមកដល់ពេលឥឡវហ្នឹងខ្ញុំវាគ្រាន់ដែរវាបា
នវាងធូរធាដែរ បានប្តីណា។
ក៖
ចាស!ចឹងអោយបងរំលឹកអំពីអតិតកាលដូចជានៅក្នុងរបបប៉ុលពតណាតើបង
ស្រីកាលជំនាន់នុងមានការរស់នៅយ៉ាងដូចម៉េចដែរ?
ខ៖ កាលជំនាន់នុង! នៅកុមារ យកបាយអោយចាស់!។
កាលនុងនៅក្មេងតូចៗនុង អាយុ៥ទៅ៦ឆ្នាំនុងគេប្រើ
គេប្រើអោយយកបាយអោយចាស់ៗណា យកបាយទៅ
ផ្ទះណាមានចាស់ចឹងទៅគេអោយយួរបាយអោយចាស់ៗចឹងទៅ
ហើយទៅនៅជាមួយនឹងក្មេងៗ នៅកុមារនុង នៅម៉ាកន្លែងនុង
ដល់ពេលបាយទៅគេគោះជួងទៅ អោយយួរបាយអោយផ្ទះណាចាស់ៗចឹង

ឃូរដាក់កាតូ ដាក់ចានយកអោយគេចឹងកាលនៅកុមារនោះ
ត្មានបានមានទាន់ធ្វើអីនោះទេ កាលនៅកុមារនោះ មិនទាន់បានធ្វើអីនោះទេ
មានធ្វើស្អី?។
ក៖ តែដល់ពេលបានដាច់មកតើបានជាលំបាកណាបងស្រី?
ខ៖ ចាសតែដល់ពេលដាច់មកហ្នឹងបានលំបាកវេទនាណាស់អ្នកគ្រូអើយ!
រកតែអង្ពស៊ីក៏ត្មានដែរ រួចគេតាមចាប់ នៅកាល៧០ដែលគេយកទៅវៃចោលនុង
ឈ្មោះណាមកក៏ហៅដែរ!
គេហៅឈ្មោះឱពុកម្តាយរបស់ខ្ញុំយកទៅវៃចោលនៅឯណោះ
ខាងភ្នំស្រីភ្នំប្រុសឯណោះ ក៏ប៉ុន្តែម៉ាក់របស់ខ្ញុំគាត់ចេះ
គាត់ជំលាស់ពីភ្នំពេញមកនៅឯស្រុក គេតាមអី! ចុកឈ្មោះយកទៅវៃចោល
គេថាជាអ្នកធ្វើការចឹងណា រួចទៅម៉ាក់របស់ខ្ញុំប្រាប់ថា
ខ្ញុំអត់ជាអ្នកធ្វើការអីនោះទេ ខ្ញុំជាអ្នកខាងនេសាទនៅតែឡានមួយមក
ហេងស្រ៊ុន! ដល់ពេលឡាន១ទៀតមកហេងស្រ៊ុន!
ម៉ាក្រុមគ្រួសាររបស់ខ្ញុំនុងយកទៅវៃចោលទាំងអស់នុងណា!
ហើយពេលនុងដូចជាគាត់បានដឹងយ៉ាងម៉េចនោះទេ
គាតបានប្រាប់ដល់កូនចៅថា៖ ហង់ដើរទៅនោះទៅ!
ហើយអាមួយដើរទៅនោះទៅ! ដល់ពេលឡានបានបើកមកហៅ គាត់ថាខ្ញុំមិនទា
ន់ទៅនោះទេ កូនរបស់ខ្ញុំមិនទាន់មកជុំ! គាត់ខ្ញុំមិនទាន់មកជុំ ! ។
ក៖ គាត់បានបំបែកកូនអស់រលីងណ៉!គាត់ឆ្លាត!
ខ៖ ហ្នឹងហើយ! គាត់បានបំបែកកូនអស់រលីង អោយទៅឆ្លាយៗទៅ
កុំអោយឡានគេ១មកហៅ ហើយឡានគេ១មកហៅ ដល់ពេលបាន២ថ្ងៃ
ឃើញខោអាវសុតតែឈាមមកវិញនុងហើយ គេថាទៅនៅឯដីថ្មី!
គេថាជំលាស់អ្នកឯនេះនុងទៅនៅឯដីថ្មី!
ដល់ពេលមកយកបងប្អូនណាគេអោយខោអាវនុងមកវិញ
ពាក់អាខោអាវនុងឈាមហើយប្រលាក់តាមអាខោអាវនុងណាបាន !
ដល់ពេលដឹង!ដឹងបាននាំគ្នារត់ទៅ ខ្ញុំនឹង ដល់ពេលចឹង គេលែងហៅនោះ
មកដល់ផ្ទះវិញ គេយកស្អីៗអស់រលីង ឆ្នាំងចាន ប្រហុក ផ្អុក់ គេយកអស់រលីង
មកវិញអត់មានអីគេស៊ីនោះទេ អាគេលែងហៅ យកទៅវៃចោលនុងនោះ។
ក៖ ហឹម!
ខ៖ ប៉ុន្តែបានម៉ាក់របស់ខ្ញុំនោះទេ បានគាត់បំបែកកូនបានទៅនេះ១ទៅនោះ១!
វេទនាណាស់ប្រវត្តិរបស់ខ្ញុំអ្នកគ្រូអើយ! ទំរាំតែបានមកដល់តាកុយហ្នឹង។
ក៖
តែមកដល់ពេលបងប្រុសបានប្រហែលជាប៉ុន្នានខែបានមកចាប់ដៃគ្នាហើយនុង
បានគាត់ដូចថាមានដែលមានបញ្ហាអីបន្តិចបន្តួចដែសបង?
ខ៖ អត់!
ក៖ អត់សោះ ចឹងអាចពឹងគាត់ទៅជាអនាគត់បាន មិនអីនោះទេណេស?
ខ៖ ចាស!
ក៖ ចឹងគាត់បានស្រលាញ់យើងបានស្មោះ?
ខ៖ ចាស!អាចពឹងបានព្រោះអីខ្ញុំមិនដែរមានបញ្ហាអីនោះផង។
ក៖ ចាស!
ខ៖ មិនដែលមានឈ្លោះប្រកែកមិនដែលប៉ះពាល់អីនោះទេ
គាត់នៅតែហៅពាក្យផ្អែមអីចឹង! ដូចគាត់និយាយថាគាត់អាណិតអីចឹង
គាត់មិធ្វើបាបនោះទេ គាត់តែយកគឺយកជាអនាគត មើលទៅកំសត់នោះពេក
ខ្ញុំនិយាយប្រាប់ប្រវត្តិប្រាប់គាត់នុង ។
ក៖ ចាស! មកដល់ពេលឥឡូវនេះមកដល់បងស្រី
ដូចថាមានបញ្ហាគ្រោះថ្នាក់ចរាចរណ៍ដោយ...។
ខ៖ ដោយទៅលក់នៅកន្លែងរោងចក្រនៅខ្វិតនុង ខ្ញុំបានទៅលក់!

ក៖ បងស្រីលក់អីគេខ្លះ?
ខ៖ លក់ទឹកអំពៅ លក់ដូង! លក់ត្រឿងកំប៉ុងហ្នឹង ហើយ ពងទាកូនតំបាវ
ខ្ញុំលក់ប៉ុន្នានមុខនុង ដល់ពេលថ្ងៃ១ដូចថាម៉ោង៨ ហើយឆ្លងខ្នល់ឡើងចើក
ហើយដល់ពេលនុងឡានឡើងទំរាប គែហើយបានដាច់ឡានហើយ
មើលទៅម៉ូតូដូចជានៅឆ្ងាយនោះទេ ដល់ពេលឆ្លងទៅ
គឺមានគេមកគាលនៅខាងក្រោយនេះ គាលបាំងទៅវាដួលបោកចឹងទៅ
ហើយបានបាក់ដៃហើយត្រេចជើងប៉ះអាត្រគៀកនេះ។
ក៖ ចាស។
ខ៖ ចឹងបានប៉ះអាត្រគៀកនេះខ្លាំងណា បានដួលទៅបោក
ហើយល្ឆូតកាលេសនុង ខ្ញុំបានទៅលក់នៅកន្លែងខ្ញុំអីនុង
អីនៅឯខាងមុខរោងចក្រនុង
ហើយគាត់យើញខ្ញុំនេះអ្នករកស៊ីដែរបានជាគាត់យក គាត់និយាយចឹង
គាត់យើញខ្ញុំរកនឹង អ្នករកស៊ីដែរ មើលទៅវាមិនខ្ជិល វាឆ្លាតអីចឹង
ហើយបានគាត់មកដាំស្លទៅ ហើយដល់ពេលទុំទៅខ្ញុំដឹកយកទៅលក់ទៅ
ដល់ពេលព្រឹកយកទៅលក់ត្រសក់ទុំទៅ ម៉ោង៨បើករោងលក់ទៅ ព្រឹកចឹងទៅ
បើកលក់ត្រសក់ទុំទៅ ម៉ោង៨បានលក់ទៅ
ដល់ពេលអស់ត្រសក់ទុំទៅបានបើករោងយកទៅលក់ចឹងទៅ
អស់ត្រសក់នុងបានប៉ះត្រកួនទៅលក់ ប៉ះត្រកួនចង់បាញ់យកទៅលក់
បោះអោយគេបាត់ចឹងទៅ ដល់ពេលម៉ោង៨ព្រឹកបានបើកលក់នុង។
បើសិនជាយើងមិនប្រឹងនោះគឺយើងនេះជំពាក់គេចឹងហើយបានបើកលក់ទៀត
ទៅ ខ្លាចចិត្តគេ ព្រោះអីគេមានហើយយើងនេះវាអត់ គែខ្ញុំបានប្រាប់គេហើយថា
ខ្ញុំអត់នោះទេ ខ្ញុំមិនចេះអួតប្រាប់គេថាចេះចុះ មានចេះចុះនោះទេ
ខ្ញុំប្រាប់គេតាមត្រង់តែម្តង ។
ក៖ ចឹងបងស្រីដូចថា បានជួបគាត់ហើយ ហើយបាននិយាយបញ្ហាហ្នឹង
ប្រាប់ដល់គាត់ហើយចឹងតើបងស្រីជំពាក់លុយគេចំនួនប៉ុន្នាន?
ខ៖ ២០០០!
ក៖ ចឹងហើយមកដល់ពេលឥឡូវហ្នឹង សង់គេ?
ខ៖ សងរួចអស់ហើយ!
ក៖ សងរួចអស់តែម្តង?
ខ៖ ចាស!
ក៖ ហើយចឹងដល់ពេលរួចទៅបាននៅផ្សំនេះបានផ្សំនោះចឹងទោ
បានសង់គេរួចអស់ គាត់បានអោយយើងយកទៅសងគេរួចអស់ចឹងទៅ
ហើយគាត់ដូចថា អោយលុយធ្វើក្រវិល អោយធ្វើខ្សែកអីចឹង
គាត់អោយធ្វើពាក់ទៅខ្ចាស់គេ កុំអោយគេថា បានខ្ញុំទៅវាអត់។
ក៖ គាត់អោយធ្វើ
ខ៖ ចាសបានធ្វើត្រឿងអល្លង្កាអោយបានពាក់អោយ។
ក៖ បាន១កំផ្លេរបានអោយពាក់ណ៉?
ខ៖ ចាស!គាត់បានអោយធ្វើចឹងទៅ បានជួយយិតយោងត្រួសារ
ក្រុមត្រួសារគេនៅឯផ្ទះនេះ កុំអោយគេថាអត់ចឹងណា។
ក៖ ចាស!
ខ៖ ព្រោះអីគាត់ក៏លាក់អំពីកូនដែរ។
ក៖ អឺម! ក៏ប៉ុន្តែចំណែកកូនរបស់គាត់ចំពោះបងស្រីគាត់ហៅ?
ខ៖ ហៅអ៊ី!
ក៖ ហៅអ៊ីហ៉?
ខ៖ ចាស! ហៅអ៊ី!មានអីកូនៗស្រលាញ់ទាំងអស់
មានតែថាពីឪរបស់វាគេរកតែប្រពន្ធរកស៊ីមិនបាន
ចឹងតើកូនឯងប្រចាណ្ឌប្រពន្ធ?

នេះឱរបស់វាហ្នឹងថាអោយ!ដល់ចឹងខ្ញុំទៅរកស៊ីទៅ
រាងយប់នោះទំរាំងតែដល់នៅសាររោងសារអីរួចនោះ ទំរាំងតែបោះច្រាសអីរួចនោះ
ព្រោះអីដាច់ហ់ ព្រោះអីយើងទៅដេញភ្ជៀវនោះវាមិនកើត។
ក៖ ចាស!
ខ៖ ដល់ចឹងទៅយប់ទៅ គេបានភរគាត់ថាណ់ ប្រពន្ធណ់មានប្រុសទៀតណ់
មិនមកផ្ទះនោះទេ កំពង់តែអោបប្រុសរឹតនៅឯនុង
ហើយចឹងក៏ជិះម៉ូតូតាមចឹងអើយ!។
ក៖ ហាសៗ!
ខ៖ ទៅជិះទៅ លប់មើល!
ក៖ អ្នកភរនុងក៏ភរបានជំនាប់ទៀត!
ខ៖ ជិះទៅរុយ ទៅតាមមើលទៅ! លប់មើលយើង
តែដល់ពេលលប់មើលយើងរាងថាយប់រាងថាដល់ពេលម៉ោង៦ហើយដើរទៅ ទើមៗ
ទៅ ហើយខ្ញុំថា ៖ហាក់! បងមកដល់ពីកាល? ហើយគាត់ថា
អូអត់ដឹងថាខ្ញុំលប់មើលយូរហើយហ់?! គេប្រាប់ថា ឯងមានប្រុស!
ហើយចឹងឯងអត់មើលនោះទេ ថាខ្ញុំនេះហត់ចង់ងាប់។
ក៖ ហាសៗ!
ខ៖ អើ! មើលហើយឃើញថាអត់មាននោះផង! កំពុងតែហត់
កំពុងតែហត់ជាមួយនឹងភ្ជៀវកាប់ដូងអោយភ្ជៀវចាប់ពងទាកូនដាក់អោយភ្ជៀវ
ហើយមាននំប៉ាវ ហើយឃើញថាប្រពន្ធអត់មានផងនុង
ចឹងវ៉ូងអាគេបាញ់នុងភរអញ!។ អូយ! ចឹងសំគេនោះបញ្ជូលថា
ចាស់ហើយយកប្រពន្ធក្មេង ហើយយកប្រពន្ធក្មេងរកតែស្អាត។ អឺ!
អញនេះទាល់តែស្អាតចឹងបានអញយក!។
ក៖ ហើយចឹងគាត់ឥឡូវអាយុប៉ុន្នានហើយ?
ខ៖ គាត់មកដល់ពេលឥឡូវនេះគាត់មានអាយុ៥៧។
ក៖ អូ! មិនទាន់ចាស់ណាស់ណានោះទេ។
ខ៖ បង៧ឆ្នាំ!
ក៖ បង៧ឆ្នាំហ្នឹង!
ខ៖ គាត់៥៧ ហើយខ្ញុំ៥០។
ក៖ ចាស!
ខ៖ ប៉ុន្តែគ្រាន់តែថា គាត់អត់អីនោះទេ
កូនចៅរបស់គាត់មិនហ៊ានជាមួយនឹងនោះទេ!
ក៖ ចាស!
ខ៖ អត់អីនោះទេ តាំងពីការហើយ មកទាល់តែឥឡូវហ្នឹង
អត់អីនោះទេគឺសុតស្រួល ដូចថាពេលប្រពន្ធគ្រោះថ្នាក់ចឹងទៅ បតជើងមិនកើត
ហើយបោកខោអាវក៏មិនកើត គាត់នុងអាចម៏នោម ហើយ
យើងដើរទៅបង្គន់មិនរួចចឹងទៅ គាត់ក៏បីទៅ ត្រាលទៅ ចឹងបានគាត់ថា
កុំសំណាងហើយចេះយកប្តីទាន់ បើសិនជាកុំយកប្តីទាន់នោះ
អាចម៏នោមរបស់អ្នកឯងប៉ាចទៅពប៉ាចនុងហើយ មានប្តីចឹងណា
ត្រៀសទៅលាងអាចម៏ទៅលាងនោមចឹងណា!
ក៖ ហ្នឹង!
ខ៖ ហើយចឹងបានស្រួលដែរ។
ក៖ ចាសគាត់ដឹងទុក្ខធុរ:យើង ចឹងពេលយើងយកគាត់ជាគូស្រករនោះគឺចឹង។
ខ៖ ចាស!
ក៖ ចឹងចេះយកគ្នាទៅវិញទៅមកចឹងហេស?
ខ៖ ចាសគាត់ដឹង!
ក៖ ចឹងបានជាគេអោយគាត់មានគូស្រករណា!

ខ៖ ចាស! ហើយដល់ពេលសព្វថ្ងៃនេះមានដៃម្ខាងចឹង ទៅមក
គាត់បានទៅលើកបាយយកទៅហូបដោយខ្លួនឯង
ហើយបើសិនជាខ្ញុំនេះដៃ១ខាងទៅចឹងទៅ ទៅដាក់ដាំទឹកអោយគាត់ផឹកចឹងទៅ
ហើយខ្ញុំបានទៅកាប់នៅចង្ក្រានអោយគាត់ចឹងទៅ
ហើយចឹងគាត់សុតចិត្តទៅកាច់ ដាក់ដាំអោយ
គាត់ថាទោះបីជាហត់ប៉ុណ្ណាក៏អត់ចេះថា។
ក៖ មកពីធ្វើចំការនុងមក មកវិញអត់មានបានថាអើយ! ហត់ចិត្តអីនោះទេ!
ចឹងអត់មានមាត់នោះទេ?
ខ៖ អត់មានមាត់នោះទេ! ថាតាដាំទឹកអស់ទឹកផឹក!
ប៉ាមុជទឹកជុសអាចម៍មិនដែរ ត្អូញមិនដែរបានភ្លាមៗតែម្តង
ហើយធ្វើយ៉ាងម៉េចក៏អោយអោយតែប្រពន្ធស្រួល! ចឹងបានបងគាត់ថា
យាយឯងនេះសំណាងហើយ ហៅប៉ាលិចប៉ាកើតចឹង ព្រោះអីប្រពន្ធមុន
ត្រាន់តែកាលេកពីខ្ពល់មកប្រចោរតែម្តងៗ នោះគាត់និយាយប្រាប់
កូនជាអ្នកនិយាយប្រាប់ ហើយមីងចៅនោះក៏ប្រាប់ ។
ក៖ ចឹងគាត់កាច?
ខ៖ ហ្នឹងហើយគាត់កាច! គាត់កាចណាស់ត្រាន់តែដល់មុនខ្ពល់នុង គឺទំលាប់ដេរ
អាគេបាញ់ អាត្រូវត្រាប់អីចឹង អាស្អីៗ អត់មានហ៊ានចូលផ្ទះនោះទេ ណ៉ វាង
នៅតាមហ្នឹងចូលទៅខាងក្រោយផ្ទះ! ហើយដេកនៅផ្ទះខាងក្រោយ
ស៊ីបាយនៅផ្ទះកូនខាងក្រោយហ្នឹង។
ក៖ ចឹងគាត់មិនមែនកាចនោះទេ គឺថាប្រពន្ធរបស់គាត់កាច?
ខ៖ ខ្ញុំនិយាយប្រពន្ធនុងណា!គាត់ស្លូតនោះទេ!
ក៖ អូ!
ខ៖ រួចដល់បានខ្ញុំ បងទៅប៉ាទៅ!! ៗ
ថាចង់ស្លាប់ហើយមិនអោយយើងធ្វើអីនោះទេ! ។
ក៖ ចឹងនេស?
ខ៖ ចាស!
ក៖ ចឹងមកឥឡូវបងមានពាក្យពេចន៍អីទៀតដេស?
ខ៖ អស់ហើយអត់មានពាក្យពេចន៍អីនោះទេ។
ក៖ ចឹងមុននឹងបញ្ចប់តើបងស្រីមានពាក្យពេចន៍អ្វីដើម្បីផ្តាំផ្ញើ
ដល់គំរូអោយកូននឹងដល់កូនចៅក្រោយៗទៀតណា?
ខ៖ ហើយអោយខំប្រឹងតស៊ូ
គឺបានបញ្ចប់គឺថាបានពាក្យពេចន៍ដែរខ្ញុំបាននិយាយទាំងប៉ុន្ទានចឹងណា
គឺដែរខ្ញុំរកស៊ីដែរខ្ញុំលំបាកនុង គឺនៅជំនាន់ក្រោយអោយដឹង
អោយដឹងប្រវត្តិដូចខ្ញុំនេះពីដើមមានការលំបាកប៉ុនណា? កំសត់ប៉ុនណា?
ចេះតស៊ូ មការហូត ដល់ចាស់! ហើយចេះតស៊ូអោយដូចខ្ញុំ
ហើយបានចេះតស៊ូអោយបានដូចជាខ្ញុំចឹង ចេះតស៊ូហើយកុំ បើសិនជាមានប្តី
ប្រពន្ធកុំឈ្លោះ កុំចោល កុំកាប់ចាក់គ្នា សូមអោយតែស្រួលគ្នា សុខសប្បាយចាស!
។
ក៖ ចាសនេស! ខុសត្រូវអីនិយាយគ្នាទៅ!
ខ៖ ខុសត្រូវអីនិយាយគ្នាទៅ កុំអោយអញ្ចហែងអីចឹង វាមិនល្អនោះទេ
ធ្វើគំរូអោយដល់ខ្ញុំទៅ។
ក៖ ចឹងមានទៀតដេស?
ខ៖ អស់ហើយបង!
ក៖ ចឹងខ្ញុំសូមអរគុណដល់បងស្រីច្រើនដែលបានលះបង់ពេលវេលា
រៀបរាប់ដំណើរជីវិតរបស់បងស្រីតាំងពីបងអឺ!
ដឹងក្តីមការហូតមកដល់ពេលបច្ចុប្បន្ទនេះ
ដើម្បីអោយបានភ្ជាប់ជាមួយនឹងបទសម្ភាស

ហើយយកទៅសកលវិទ្យាល័យនៅBYUនៅUSA
តើបងស្រីអនុញ្ញាតអោយអ្នកនយកទៅដាក់នៅក្នុងគេហ:ទំព័រហ្នឹងបានដែរឬទេ?
ខ៖ បាន!
ក៖ ចាសចឹង!
ខ៖ ដើម្បីជំនាន់ក្រោយ!
ក៖ ចាស!
ខ៖ អោយគេតស៊ូដូចជំនាន់មុន ដូចថាអោយគេយកចាស់ៗជាគំរូតាមហ្នឹង ។
ក៖ ចាស!
ខ៖ បានអោយដាក់!
ក៖
ចាសចឹងខ្ញុំសូមប្រសិទ្ធិពរដល់បងស្រីអោយជួបតែពុទ្ធប្រការគឺអាយុវណ្ណ:សុខ:ពល:កុំប្បីឃ្លានឃ្លាតឡើយ!។
ខ៖ ចាសអរគុណ!
ក៖ ចាសអរគុណច្រើនជំរាបលា!
ខ៖ ចាស!។